នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០៤/០៧-០៩-២០០៩-អវតក/កសចស(អបជ ៦១) |
| ដាក់ទៅ | ៖ | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | ៖ | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | ៖ | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | ៖ | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖ សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Oct-2019, 10:35
CMS/CFO: Ly Bunloung

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង 004 (D382)

**អ្នកដាក់ឯកសារ៖**
លោកស្រី Brenda J. Hollis
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន:**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤**

**សហមេធាវី យឹម ទិត្យ**
លោក សូ ម៉ូស្សេនី
លោក Suzana TOMANOVIĆ

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ចោទប្រកាន់ យឹម ទិត្យ ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ព្រមទាំងការរំលោភទៅលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងឱ្យបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1]។ ក្នុងថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាសម្រេចលើកលែងចោទប្រកាន់") លើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង យឹម ទិត្យ ដោយរកឃើញថា គាត់មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ទេ[2]។ សហព្រះរាជអាជ្ញាជាតិ ("ស.ព.ជ") បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ") ដោយនៅតែរក្សាជំហរថា អ.វ.ត.ក គ្មានយុត្តាធិការបុគ្គលលើ យឹម ទិត្យ[3]ទេ។ ពេលនេះ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ធ្វើការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ជាភាសាអង់គ្លេសជាមុនសិន ដោយដាក់ឯកសារបកប្រែជាភាសាខ្មែរតាមក្រោយឱ្យបានលឿនតាមដែលអាចធ្វើទៅបាន[4]។ ច្បាប់ជាធរមានត្រូវបានលើកឡើងនៅក្នុងផ្នែកពាក់ព័ន្ធនានាខាងក្រោមនេះ។

## II. សេចក្តីសន្និដ្ឋាន

[1] ឯកសារ **D382** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") KH 01624968-81។ ការបកប្រែជាភាសាខ្មែរនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩។

[2] ឯកសារ **D381** ដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ដីកាសម្រេចលើកលែងការចោទប្រកាន់") កថាខណ្ឌ ៦៨៤, ៦៨៦-៦៨៧។ ការបកប្រែជាភាសាអង់គ្លេសនៃដីកាសម្រេចលើកលែងការចោទប្រកាន់នេះ ត្រូវបានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩។

[3] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ") កថាខណ្ឌ ៧៥-៧៦។

[4] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ត្រូវបានដាក់ពីដំបូងជាភាសាខ្មែរ និងមានការបកប្រែជាភាអង់គ្លេសតាមក្រោយ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ធ្វើឱ្យចម្លើយតបនេះត្រូវដល់កាលកំណត់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ អនុលោមតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិ. លើកទី៨) ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ មាត្រា ៨.៣, ៨.៥។ ស.ព.អ ស្នើសុំការអនុញ្ញាតដាក់ជាភាសាអង់គ្លេសជាមុនសិន នៅក្នុងឯកសារ D382/14 សំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាអង់គ្លេសជាមុនសិន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩។

2. ស.ព.អ សន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ (i) មិនត្រូវតាមបទដ្ឋាននៃការត្រួតពិនិត្យលើបណ្តឹងឧទ្ធរណ៍នោះទេ ដោយហេតុថា បណ្តឹងនេះមិនបានបង្ហាញពីកំហុសអង្គច្បាប់ ឬ កំហុសអង្គហេតុណាមួយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬថា ស.ច.ស.អ បានបំពានលើឆន្ទានុសិទ្ធិរបស់គាត់នៅក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង យឹម ទិត្យ។ (ii) បានលើកឡើងពីនិយមន័យនៃយុត្តាធិការបុគ្គល ដែលមិនគោរពតាមចេតនាដែលបានបញ្ជាក់យ៉ាងច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ("អ.ស.ប")។ (iii) ខកខានមិនបានបកស្រាយបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាមានអំណាចកម្រិតជាឯកតោភាគីលើយុត្តាធិការបុគ្គល ដោយមិនបានធ្វើវិសោធនកម្មត្រឹមត្រូវតាមច្បាប់លើកិច្ចព្រមព្រៀង អ.វ.ត.ក និង (iv) បានអះអាងដោយមិនឲ្យជឿបានថា សំណុំរឿង០០១ និង ០០២ បាននាំមកនូវវិធានការយុត្តិធម៌គ្រប់គ្រាន់ និងជាការរួមចំណែកដល់ការផ្សះផ្សារជាតិ។

## ក. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ខកខានមិនបានបំពេញតាមបទដ្ឋាននៃការត្រួតពិនិត្យលើបណ្តឹងឧទ្ធរណ៍

3. វិធាន ៧៥(៤) នៃវិធានផ្ទៃក្នុងបានកំណត់យ៉ាងច្បាស់ថា សារណាបណ្តឹងឧទ្ធរណ៍ "ត្រូវមានបញ្ជាក់អំពីអំណះអំណាងខាងអង្គហេតុ និងអង្គច្បាប់ ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍"[5]។ ដូចអង្គជំនុំជម្រះធ្លាប់បានសម្រេចជាឯកច្ឆន្ទថា[6] សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ ដូចជា ការកំណត់

[5] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិ.លើកទី៩) ដែលបានកែប្រែ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥, វិធាន ៧៥(៤)។ *សូមមើលផងដែរ* សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ("សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ ១០៤ ("វិសាលភាពនៃការពិនិត្យបណ្តឹងឧទ្ធរណ៍ [នៅចំពោះមុខ អ.ប.ជ] ត្រូវបានកម្រិតចំពោះតែបញ្ហានានាដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះ")។

[6] សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ(សំអាងហេតុ), ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨, កថាខណ្ឌ ២១ (ការសម្រេចជាឯកច្ឆន្ទ)។ *សូមមើលផងដែរ* សំណុំរឿង ០០២-ឯកសារ **D427/1/30** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ១១២-១១៣, និង ការយោងនានានៅក្នុងនោះ។ *រដ្ឋអាជ្ញា ទល់នឹង Brđanin*, IT-99-36-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ (សាលដីកាលើសំណុំរឿងរបស់ *Brđanin*), កថាខណ្ឌ ៧-៩ (យោងមាត្រា ២៥ នៃច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY និងច្បាប់យុត្តិសាស្ត្រនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ទាំងពីរ គឺ ICTY និង ICTR)។ *រដ្ឋអាជ្ញា ទល់នឹង Rutaganda*, ICTR-96-3-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣, (សាលដីកាលើសំណុំរឿងរបស់ *Rutaganda*), កថាខណ្ឌ ១៧-១៨ (យោងទៅរកមាត្រា ២៤ នៃច្បាប់លក្ខន្តិកៈរបស់តុលាការ ICTR)។

ថាតើជនត្រូវចោទណាម្នាក់ស្ថិតនៅក្នុងប្រភេទនៃជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យ អាចនឹងត្រូវបានកែប្រែឡើងវិញ តែក្នុងករណីបានពឹងផ្អែកលើកំហុសអង្គច្បាប់ ដែលនាំឱ្យអស់សុពលភាពដល់សេចក្ដីសម្រេច ឬកំហុសខាងអង្គហេតុដែលបើកឱកាសឱ្យមានការខុសឆ្គងរបស់តុលាការ និង/ឬ មានភាពមិនត្រឹមត្រូវ ឬមិនសមហេតុផលយ៉ាងខ្លាំង ដែលជាការរំលោភបំពានលើឆន្ទានុសិទ្ធិ[7]។

[7] មានការកំណត់យ៉ាងច្បាស់នៅ អ.វ.ត.ក និងនៅក្នុងច្បាប់អន្តរជាតិដែលថា បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬសាលក្រម/សាលដីកាដែលខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវអប្បបរិមាទាំងនេះ អាចត្រូវបានច្រានចោលជារួម ដោយពុំចាំបាច់មានការដេញដោលណាមួយទៅលើអង្គសេចក្ដីនោះទេ។ *សូមមើល ជាឧទាហរណ៍* សំណុំរឿង០០១-ឯកសារ **F28** សាលដីកាលើបណ្ដឹងសាទុក្ខ, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីការបស់ ឌុច"), កថាខណ្ឌ ២០ ("អំណះអំណាងរបស់ភាគីមួយដែលគ្មានសក្ដានុពលដែលអាចធ្វើឱ្យសេចក្ដីសម្រេចដែលរងការជំទាស់ អាចត្រូវបានសើរើឡើងវិញ ឬកែប្រែឡើងវិញ អាចនឹងត្រូវបានទាត់ចោលភ្លាមៗដោយអង្គជំនុំជម្រះតុលាការកំពូល និងដោយពុំចាំបាច់ពិចារណាទៅលើអង្គសេចក្ដីឡើយ។ [...] អង្គជំនុំជម្រះតុលាការកំពូលអាចច្រានចោលអំណះអំណាងទាំងឡាយដែលគ្មានមូលដ្ឋានជាក់ស្ដែង ដោយពុំចាំបាច់ផ្ដល់សំអាងហេតុលម្អិត")។ សាលដីកាលើសំណុំរឿងរបស់ *Rutaganda*, កថាខណ្ឌ ១៨, ("ជាគោលការណ៍ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ មិនតម្រូវឱ្យពិចារណាលើអំណះអំណាងរបស់ភាគីណាមួយដែលមិនបានចោទប្រកាន់អំពីកំហុសខាងអង្គច្បាប់ ដែលនាំឱ្យអស់សុពលភាពនៃសេចក្ដីសម្រេច ឬកំហុសអង្គហេតុដែលនាំឱ្យមានការខុសឆ្គងរបស់តុលាការទេ [...]។ អាស្រ័យហេតុនេះ បើតាមកត្តវិជ្ជា ប្រសិនបើអំណះអំណាងដែលបានបង្ហាញដោយភាគីមួយមិនមានសក្ដានុពលក្នុងការធ្វើឱ្យសេចក្ដីសម្រេចដែលរងការជំទាស់នឹងត្រូវបានសើរើ ឬកែប្រែទេនោះ នោះអង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចច្រានចោលភ្លាមៗនូវអំណះអំណាងទាំងនោះ ថាជាការយល់ខុស ហើយមិនចាំបាច់នឹងពិចារណាទៅលើអង្គសេចក្ដីរបស់វាឡើយ")។ *រដ្ឋអាជ្ញា ទល់នឹង* *Krajišnik*, IT-00-39-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩, (សាលដីកាលើសំណុំរឿងរបស់ *Krajišnik*), កថាខណ្ឌ ១៦ ("ដើម្បីឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍វាយតម្លៃលើអំណះអំណាងក្នុងបណ្ដឹងឧទ្ធរណ៍របស់ភាគីណាមួយបាន ភាគីនោះត្រូវបានគេរំពឹងថា នឹងបង្ហាញករណីរបស់ខ្លួនឱ្យបានច្បាស់លាស់ មានតក្កភាព និងគ្រប់សព្វ។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ អាចច្រានចោលសារណានានាបានដោយមូលហេតុគ្មានមូលដ្ឋាន ដោយពុំចាំបាច់ផ្ដល់សំអាងហេតុលម្អិត ប្រសិនបើសារណារបស់ភាគីនោះមិនច្បាស់ ផ្ទុយ ស្រពេចស្រពិល ឬទទួលរងពីភាពខ្វះខាតជាផ្លូវការ និងជាក់ស្ដែងដទៃទៀត") កថាខណ្ឌ ១៨, ២០។ សាលដីកាលើសំណុំរឿងរបស់ *Brđanin*, កថាខណ្ឌ ១៦ ("អំណះអំណាងរបស់ភាគីមួយដែលគ្មានមូលដ្ឋានជាភ័ស្តុតាង ឬ គ្មានសក្ដានុពលក្នុងការធ្វើឱ្យសេចក្ដីសម្រេចរងការជំទាស់ត្រូវបានសើរើឡើងវិញ ឬកែប្រែឡើងវិញ អាចនឹងត្រូវបានច្រានចោលជាបន្ទាន់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ និងមិនចាំបាច់មានការពិចារណាទៅលើអង្គសេចក្ដីទេ"), កថាខណ្ឌ ១៩-៣១ (រាយឈ្មោះប្រភេទអំណះអំណាងនៃបណ្ដឹងឧទ្ធរណ៍ចំនួនប្រាំបីដែលនឹងត្រូវទាត់ចោលដោយសរុបរួមសេចក្ដី រួមមាន អំណះអំណាងដែលមិនពាក់ព័ន្ធយ៉ាងច្បាស់ក្រឡែត ឬផ្ដល់ការគាំទ្រដល់ការរកឃើញដែលបានតវ៉ា ឬដែលផ្ទុយទៅនឹងការយល់ដឹងត្រឹមត្រូវ)។ *រដ្ឋអាជ្ញា ទល់នឹង* *Kunarac* និងគូកន, IT-96-23 & IT-96-23/1-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ ("សាលដីកាលើសំណុំរឿងរបស់ *Kunarac*"), កថាខណ្ឌ ៤៨។ *រដ្ឋអាជ្ញា ទល់នឹង* *Vasiljević*, IT-98-32-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤, កថាខណ្ឌ ១០, ១៦-២៣។

4. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ គួរតែត្រូវបានបដិសេធចោល ដោយសារបណ្តឹងនេះមិនបានលើកឡើងពីមូលដ្ឋានបណ្តឹងឧទ្ធរណ៍ច្បាស់លាស់ ដែលលើកឡើងយ៉ាងច្បាស់លាស់ និងជាក់លាក់អំពីកំហុសផ្នែកអង្គច្បាប់ ឬ អង្គហេតុ ឬក៏មិនបានពន្យល់ថា ហេតុអ្វីបានជាកំហុសនោះ នឹងធ្វើឱ្យអស់សុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬនាំឱ្យមានការខុសឆ្គាយរបស់តុលាការ ហើយខកខានមិនបានចោទប្រកាន់ថា ស.ចៅ.ស.អ បានរំលោភបំពានឆន្ទានុសិទ្ធិរបស់គាត់ក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[8]។ ទោះជាបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ មានលើកឡើងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងសេចក្តីផ្តើមក៏ពិតមែន[9] តែមិនបានយោង ដកស្រង់ ឬសំដៅទៅរកពាក្យនេះនៅកន្លែងផ្សេងទៀតទេ។ ផ្ទុយទៅវិញ បណ្តឹងឧទ្ធរណ៍នេះគ្រាន់តែបានធ្វើសេចក្តីសន្និដ្ឋានទូទៅនានា ដែលជាញឹកញាប់ ពុំមានទំនាក់ទំនងដោយផ្ទាល់ ឬច្បាស់លាស់ទាល់តែសោះជាមួយនឹងសេចក្តីសម្រេចខាងផ្លូវច្បាប់ ឬខាងអង្គហេតុ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយគ្រាន់តែលើកឡើងវិញម្តងទៀតថា "ស.ព.ជ នៅតែពិចារណាថា យឹម ទិត្យ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក"[10]។

## ១. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ខកខានមិនបានបង្ហាញអំពីកំហុសខាងអង្គហេតុទេ

---

[8] *សូមមើល* សាលដីកាលើសំណុំរឿងរបស់ *Kunarac*, ("ហេតុដូច្នេះ វាត្រូវធ្លាក់ទៅលើភាគីដែលកំពុងបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៅក្នុងការបង្ហាញករណីរបស់ខ្លួនឱ្យបានច្បាស់លាស់ មានតក្កភាព និងសព្វគ្រប់ ដើម្បីឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចបំពេញអាណត្តិរបស់ខ្លួនឱ្យមានប្រសិទ្ធិភាព និងឆាប់រហ័ស។ គេមិនអាចរំពឹងទុកថាអង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចផ្តល់ការពិចារណាមួយយ៉ាងពិស្តារទៅលើសារណារបស់ភាគីនានាបានឡើយ ប្រសិនបើសារណានោះមានភាពមិនច្បាស់ ផ្ទុយ ស្រពេចស្រពិល ឬប្រសិនបើទទួលរងពីភាពខ្វះខាតជាផ្លូវការ និងជាក់ស្តែងដទៃទៀត។ [...] អាស្រ័យហេតុនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវតែចែងឱ្យបានច្បាស់លាស់អំពីទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍របស់ខ្លួន ក៏ដូចជាអំណះអំណាងដទៃទៀតដែលគាំទ្រដល់ទឡ្ហីករណ៍នីមួយៗ")។ *រដ្ឋអាជ្ញា ទល់នឹង Kupreškić*, IT-95-16-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១, កថាខណ្ឌ ២៧ ("ភាគីដែលធ្វើសារណាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងអង្គច្បាប់ ត្រូវតែយ៉ាងហោចណាស់បង្ហាញពីអត្តសញ្ញាណនៃកំហុសដែលខ្លួនចោទប្រកាន់នោះ និងត្រូវបង្កើនអំណះអំណាងមួយចំនួនដើម្បីគាំទ្រដល់ការតវ៉ារបស់ខ្លួន។ គេមិនអនុញ្ញាតឱ្យមានបណ្តឹងឧទ្ធរណ៍ណាមួយចូល ទៅក្នុងល្បែងទោះទាយសម្រាប់អង្គជំនុំជម្រះសាលាបានឡើយ។ [...] យ៉ាងហោចណាស់ ប្រសិនបើភាគីមិនអាចកំណត់កំហុសខាងអង្គច្បាប់ដែលខ្លួនបានចោទប្រកាន់នោះទេ គាត់ក៏មិនអាចលើកពីអំណះអំណាងនៅក្នុងបណ្តឹងឧទ្ធរណ៍នោះដែរ")។ សាលដីកាលើសំណុំរឿងរបស់ *Krajišnik*, កថាខណ្ឌ ២៦។ សាលដីកាលើសំណុំរឿងរបស់ *Rutaganda*, កថាខណ្ឌ ១៩។ សំណុំរឿង ០០១-**F28** សាលដីកាលើសំណុំរឿងរបស់ ឌុច កថាខណ្ឌ ២០។

[9] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ, កថាខណ្ឌ ១-២, ៤-៥។

[10] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ, កថាខណ្ឌ ៧៥។

5. ផ្នែកដំបូងនៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ផ្នែក "សារណា" ពិភាក្សាអំពីការបង្កើតបក្សកុម្មុយនិស្តកម្ពុជា ("ប.ក.ក") និងបានផ្តល់ព័ត៌មានស្តីពីមហាសន្និបាតបក្ស និងគណៈកម្មាធិការរបស់បក្ស ការដឹកនាំរបស់បក្សកម្មុយនិស្តកម្ពុជា រចនាសម្ព័ន្ធរដ្ឋបាលរបស់ភូមិភាគ និងសាវតារ ព្រមទាំងតួនាទីរបស់ យឹម ទិត្យ នៅក្នុងស្រុកគីរីវង្ស និងនៅភូមិភាគពាយ័ព្យ[11]។ ការអះអាងខាងអង្គហេតុនៅក្នុងផ្នែកនេះជាញឹកញាប់ត្រូវបានលើកឡើងតាមរបៀបសន្និដ្ឋាន ដោយពុំមានលើកឡើងពីប្រភពគាំទ្រផ្នែកភស្តុតាងនោះទេ[12] ឬក៏គ្រាន់តែស្វែងរកភស្តុតាងផ្ទុយនៅក្នុងសំណុំរឿងតែប៉ុណ្ណោះ[13]។ សំខាន់ជាងនេះទៀត មិនមានការអះអាងណាមួយក្នុងចំណោមការអះអាងទាំងនេះ បានយោងទៅផ្នែកណាមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយក៏មិនមានអំណះអំណាងណាមួយថាតើហេតុអ្វីបានជា ស.ច.ស.អ មានការខុសឆ្គងនោះដែរ។ ដោយគ្រាន់តែផ្តល់ការបកស្រាយភស្តុតាងមួយ[14] បានខកខានមិនបានបំពេញកាតព្វកិច្ចរបស់ដើមបណ្តឹងឧទ្ធរណ៍

---

[11] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ, កថាខណ្ឌ ១៩-២៣ (ការបង្កើត ប.ក.ក), ២៤-២៨ (មហាសន្និបាតបក្ស និងគណៈកម្មាធិការ), ២៩-៣៣ (ការដឹកនាំរបស់ ប.ក.ក), ៣៤-៤៤ (រចនាសម្ព័ន្ធរដ្ឋបាលរបស់ភូមិភាគ), ៤៥-៤៦ (សាវតាររបស់ យឹម ទិត្យ), ៤៧-៤៨ (តួនាទីរបស់ យឹម ទិត្យ នៅក្នុងស្រុកគីរីវង្ស), ៤៩-៥១ (តួនាទីរបស់ យឹម ទិត្យ នៅភូមិភាគពាយ័ព្យ)។

[12] *សូមមើល ជាឧទាហរណ៍* ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ, កថាខណ្ឌ ១៩-៣៣, ៣៥-៤៤ និង ៤៩-៥១ ដែលពុំមានកំណត់សម្គាល់ជើងទំព័រ ឬអ្វីទាំងអស់ ដើម្បីគាំទ្រដល់ការអះអាងដែលបានធ្វើឡើងនៅក្នុងអត្ថបទ។ *សូមមើលផងដែរ* កថាខណ្ឌ ៥៥-៥៨, ៦៨-៦៩។

[13] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ, កថាខណ្ឌ ៤៦ ("មានសាក្សី[ម្នាក់]បានបញ្ជាក់ថា តាទិត្យ គឺជាមនុស្សខ្លាំងបំផុតម្នាក់ ប៉ុន្តែមានសាក្សីផ្សេងទៀតបានបញ្ជាក់ផងដែរ តាទិត្យជាមនុស្សមានចរិតស្លូតបូត ជាមនុស្សត្រឹមត្រូវ និងស្មោះត្រង់"), ៤៧ (ដោយការថ្លែងថាមានមន្ទីរស្រុកគិរីវង់ចំនួនពីរ ប៉ុន្តែពិភាក្សាភស្តុតាងចំនួនបួនកន្លែង), ៤៨ និង ៥១ (ដោយការលើកឡើងពីសាក្សីចំនួនបួនរូប ដែលបាននិយាយថា តាទិត្យ ត្រូវបានបញ្ជូនទៅបាត់ដំបងនៅប្រហែលពាក់កណ្តាលឆ្នាំ១៩៧៧ ប៉ុន្តែក្រោយមក អះអាងថា ពុំមានភស្តុតាងណាគាំទ្រទេថា យឹម ទិត្យ បានមកដល់ភូមិភាគពាយ័ព្យ បានប្រហែល៨ខែមុនថ្ងៃបញ្ចប់របប)។

[14] *សូមមើល ជាឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Krnojelac*, IT-97-25-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣, កថាខណ្ឌ ២២ ("មេធាវីការពារក្តីគ្រាន់តែឲ្យដឹងអំពីការបកស្រាយមួយផ្សេងទៅលើភ័ស្តុតាង និងមិនបានបង្ហាញពីរបៀបដែលការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសនោះទេ [...] សារណាត្រូវតែបង្ហាញឲ្យឃើញផងដែរអំពីកំហុសតាមដែលអាចធ្វើបាន [...], មិនមែនតាមរយៈការយោងទៅរកការបកស្រាយភ័ស្តុតាងដែលអាចធ្វើបាន នោះទេ")។ *រដ្ឋអាជ្ញា ទល់នឹង Simić,* IT-95-9-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦, កថាខណ្ឌ ១៤ ("ការជំទាស់ត្រូវបានបដិសេធ ដោយពុំមានសំអាងហេតុពិស្តារ កាលណា [...] អំណះអំណាងរបស់ភាគីដើមបណ្តឹងឧទ្ធរណ៍បានស្វះស្វែងរកការផ្លាស់ប្តូរមួយដែលពុំអាចទទួលយកបាន នូវការវាយតម្លៃរបស់ខ្លួនផ្ទាល់លើភស្តុតាងរបស់[អ្នកដែលរកឃើញនូវអង្គហេតុ]នោះ)")។ *រដ្ឋអាជ្ញា ទល់នឹង Halilović*, IT-01-48-

ក្នុងការកំណត់ឲ្យបានច្បាស់លាស់ពីការសម្រេចខាងអង្គហេតុដែលត្រូវបានជំទាស់[15] ឬបង្ហាញថា ពុំមានអ្នកវិនិច្ឆ័យអង្គហេតុសមហេតុផលណាម្នាក់ ដែលអាចឈានដល់ការសម្រេចបែបដូច្នោះ ដែលនាំឲ្យមានការខុសឆ្គងរបស់តុលាការនោះឡើយ[16]។

A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧, កថាខណ្ឌ ១២។ សាលដីកាលើសំណុំរឿងរបស់ *Krajišnik*, កថាខណ្ឌ ២៧។ សាលដីកាលើសំណុំរឿងរបស់ *Kunarac*, កថាខណ្ឌ ៤៨។

[15] *សូមមើល ជាឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង* Martić, IT-95-11-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨, កថាខណ្ឌ ១៨ (“អង្គជំនុំជម្រះសាលាឧទ្ធរណ៍រម្លឹកថា ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានរំពឹងថា នឹងធ្វើការបង្ហាញអត្តសញ្ញាណនៃការរកឃើញខាងអង្គហេតុដែលតវ៉ានោះ និងដាក់អំណះអំណាងខាងអង្គហេតុរបស់ខ្លួនដោយមានការយោងចំៗទៅរកលេខទំព័រ និងលេខកថាខណ្ឌ[...]។ តាមវិធានទូទៅ បើសិនជាសេចក្តីយោងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍គ្មានការយោងទៅរកសាលក្រមសាលាដំបូងទេ ឬក៏យោងមិនច្បាស់ ឬមិនត្រឹមត្រូវ នោះអង្គជំនុំជម្រះសាលាឧទ្ធរណ៍នឹងទាត់ចោលដោយសង្ខេបទៅលើការកំហុសដែលបានចោទប្រកាន់ ឬក៏អំណះអំណាងនោះ”)។ សេចក្តីសម្រេចខាងអង្គហេតុសំខាន់ៗដែលមិនអាចជំទាស់បាន ដែលបានជួយដល់ ស.ច.ស.អ ឲ្យបង្កើតយុត្តាធិការបុគ្គលទៅលើ យឹម ទិត្យ រួមមាន ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៣២៧-៣៥២ (លំអិតពីមុខងាររបស់ យឹម ទិត្យ នៅស្រុកគិរីវង់ និងនៅក្នុងគណៈកម្មាធិការ តំបន់១៣ ក្នុងកំឡុងពេលកាន់កាប់របស់គាត់នៅភូមិភាគនិរតី ដោយបានថ្លែងថា ចំណងគ្រួសារយ៉ាងជិតស្និទ្ធរបស់គាត់ទៅនឹង តាម៉ុក បានផ្តល់ដល់គាត់នូវសិទ្ធិអំណាច “ដ៏សំខាន់” បន្ថែមទៀតពីលើមុខងារផ្លូវការរបស់គាត់ ដោយបានបន្ថែមការទទួលខុសត្រូវនៅកម្រិតភូមិភាគ និងបន្តសិទ្ធិអំណាចរបស់គាត់គ្របដណ្តប់ទៅដល់កន្លែង រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ), ៣៥៣-៣៦៣ (រកឃើញថា យឹម ទិត្យ បានធ្វើការជាមួយនឹង តាម៉ុក នៅក្នុងភូមិភាគពាយ័ព្យ ចាប់តាំងពីដើមពាក់កណ្តាលឆ្នាំទៅចុងឆ្នាំ១៩៧៦ រហូតដល់ចុងបញ្ចប់នៃរបប ទោះបីជាអង្គហេតុដែលថា វាមិនមែនរហូតដល់ខែមិថុនា ឆ្នាំ១៩៧៨ ដែលគាត់ត្រូវបានតែងតាំងតាមផ្លូវការ ជាលេខាតំបន់១, ៣ និង ៤ និងជា អនុលេខាភូមិភាគពាយ័ព្យ), ៣៦៤-៣៨៥ (លំអិតពីសិទ្ធិអំណាចដែលថា យឹម ទិត្យ នៅពេលដែលបានតែងតាំងបានអនុវត្តនូវមុខងារតាមផ្លូវការរបស់គាត់), ៣៨៦-៣៨៧ (លំអិតពីការចូលរួមចំណែករបស់ យឹម ទិត្យ ទៅនឹងសហឧក្រិដ្ឋកម្មរួម ក្នុងការស្វែងរកបំបាត់ពួកខ្មែរក្រោម), ៣៨៨-៤១១ (រកឃើញថា យឹម ទិត្យ ដើរតួសំខាន់មួយ នៅក្នុងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងកសិកម្មរបស់ ប.ក.ក នៅក្នុងភូមិភាគពាយ័ព្យ), ៤១២-៤២៦ (លំអិតពីតួនាទីរបស់ យឹម ទិត្យ នៅក្នុងការជួយសម្របសម្រួលការបោសសម្អាតនៅភូមិភាគពាយ័ព្យ រួមមានការចេញបញ្ជាដាក់លាក់នានាឲ្យសម្លាប់), ៤២៧ (រកឃើញថា យឹម ទិត្យ បានចូលរួមចំណែកនៅក្នុងគោលនយោបាយរបស់ ប.ក.ក ស្តីពីការ រៀបចំឲ្យមានអាពាហ៍ពិពាហ៍), ៤៣៣-៥៨៥ (លំអិតពីឧក្រិដ្ឋកម្មនានានៅតំបន់១៣ នៅមន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខ ក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្សភូមិព្រេល ទីតាំងសម្លាប់មនុស្សវត្តអង្គណ ទីតាំងសម្លាប់មនុស្សនៅព្រៃភូមិស្លែង ទីតាំងសម្លាប់ មនុស្សវត្តអង្គសិរីមុនី និង ព្រៃសុខុន), ៥៨៦-៧៤៦ (លម្អិតពីឧក្រិដ្ឋកម្មនៅតំបន់១ នៃភូមិភាគពាយ័ព្យ នៅមន្ទីរសន្តិសុខ គាស់ក្រឡ សហករណ៍ធិបតេយ្យ ការដ្ឋានទំនប់កង្ហត មន្ទីរសន្តិសុខបាណន់ មន្ទីរសន្តិសុខខ្នងគូ ការដ្ឋានរោងចក្រស្ករស កំពង់គល់), ៧៤៧-៨២៦ (លម្អិតពីឧក្រិដ្ឋកម្មនៅតំបន់២ នៃភូមិភាគពាយ័ព្យ នៅមន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ និង ទីតាំងសម្លាប់មនុស្សព្រៃក្របៅ), ៨២៩-៨៤៩ (លម្អិតពីឧក្រិដ្ឋកម្មនៅតំបន់៣ នៃភូមិភាគ ពាយ័ព្យ នៅមន្ទីរសន្តិសុខវត្តគីរីរម្យ), ៨៥០-៩២០ (លម្អិតពីឧក្រិដ្ឋកម្មនៅតំបន់៤ នៃភូមិភាគពាយ័ព្យ នៅមន្ទីរសន្តិសុខ វត្តសម្តេច មន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ និងផ្តោតគោលដៅទៅលើពួក ខ្មែរក្រោមនៅឃុំកំពង់ព្រៀង

## ២. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ខកខានមិនបានបង្ហាញអំពីកំហុសខាងអង្គច្បាប់ទេ

6. នៅក្នុងផ្នែកទីពីរនៃផ្នែក "សារណា" បានអះអាងថា ហេតុអ្វីបានជា នៅក្នុងទស្សនៈរបស់ ស.ព.ជ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") គួរបដិសេធសំណុំរឿងនេះចោល ដោយមូលហេតុមិនមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ[17]។ តាមរយៈការសន្និដ្ឋានស្ទើរតែទាំងស្រុង មានការពិភាក្សាពីគោលនយោបាយខ្មាំងរបស់ ប.ក.ក[18] លើកឡើងថា ប្រភេទនៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សំដៅទៅ "តែប្រធានមន្ទីរសន្តិសុខស-២១ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច"[19] ប៉ុណ្ណោះ ដោយអះអាងថា ការលើកឡើងចោទប្រកាន់របស់ ស.ព.អ ប្រឆាំងនឹង យឹម ទិត្យ ធ្វើតាមតែចិត្ត និងខកខានមិនបានបញ្ជាក់ "ថាតើ យឹម ទិត្យ ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ឬស្វម្បីតែតួនាទីរបស់ យឹម ទិត្យ ក្នុងជួរកងទ័ព" ក៏គ្មានដែរ[20] និងអះអាងថា យឹម ទិត្យ មិនមានសិទ្ធិអំណាចអ្វីទាំងអស់ និងគ្រាន់តែដើរតាមមាគ៌ារបស់បក្សប៉ុណ្ណោះ[21]។ មិនមានការអះអាងណាមួយក្នុងចំណោមការអះអាងទាំងនេះត្រូវបានបង្ហាញដោយភស្តុតាងនោះទេ[22] មិនមានកំហុសឆ្គងណាមួយត្រូវបានលើកឡើងនោះទេ មិនមានការពន្យល់ណាមួយត្រូវបានផ្តល់ឲ្យនោះទេទាក់ទងនឹងការលើកឡើងចោទប្រកាន់"ស្រេចតែចិត្ត"នោះ ហើយពុំមានយោងទៅដល់អ្វីដែល

---

និងឃុំវាំងកេសី), ៩២១-៩៤៨ (លម្អិតពីឧក្រិដ្ឋកម្មនៅតំបន់៧ នៃភូមិភាគពាយ័ព្យ នៅគុកលេខ៨ និង ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង), ៩៤៩-៩៩១ (លម្អិតពីអាពាហ៍ពិពាហ៍ដោយបង្ខំ នៅតំបន់១ និង តំបន់៤)។

[16] *សូមមើល ជាឧទាហរណ៍* សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៣។ *រដ្ឋអាជ្ញា ទល់នឹង* *Haradinaj* និងគូកន IT-04-84-A សាលដីកា អង្គជំនុំជម្រះ សាលាឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ១២។ សាលដីកាលើសំណុំរឿងរបស់ *Krajišnik* កថាខណ្ឌ ១៤។ សាលដីកាលើសំណុំរឿងរបស់ *Brđanin* កថាខណ្ឌ ១៩ (ការខុសឆ្គងរបស់តុលាការ "ត្រូវបានកំណត់និយមន័យថាជា "លទ្ធផលនាំឲ្យមានភាពអយុត្តិធម៌យ៉ាងធំនៅក្នុងដំណើរនីតិវិធីតុលាការ សូម្បីតែនៅពេលដែលចុងចោទត្រូវបានកាត់ឲ្យជាប់ទោស ទោះជាមានកង្វះភស្តុតាងអំពីធាតុផ្សំសំខាន់នៃបទល្មើសក៏ដោយ")។

[17] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៥៣-៧៥។

[18] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៥៣-៥៨ (លើកឡើងតែពីភស្តុតាងនៅក្នុងកថាខណ្ឌ ៥៣ និង ៥៤ ប៉ុណ្ណោះ)។

[19] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៦៦។

[20] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៧៤។

[21] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៧៤។

[22] លើកលែងតែ ភស្តុតាងទាក់ទងនឹងសេចក្តីសម្រេចកម្ទេច ក្នុងជួរ និងក្រៅជួរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ *សូមមើល* ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៥៣-៥៤។

ត្រូវបានធ្វើឡើងនៅក្នុងដីកាដំណោះស្រាយ ដើម្បីជំទាស់ទៅនឹងការរកឃើញខាងអង្គច្បាប់សំខាន់ៗ ដែលថា បើសិនជាត្រូវបានបដិសេធនោះ នឹងធ្វើឲ្យទៅជាមោឃៈលើសេចក្តីសន្និដ្ឋានរបស់ ស.ច.ស.អ ដែលថា យឹម ទិត្យ គឺជាមនុស្សម្នាក់ក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[23]។ ដូច្នេះ បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ខកខានមិនបានបំពេញតាមបទដ្ឋានចាំបាច់ ដើម្បីបង្ហាញថា មានកំហុសខាងអង្គច្បាប់ណាខ្លះនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ទេ។

## ៣. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ខកខានមិនបានបង្ហាញថា ស.ច.ស.អ បានបំពានលើឆន្ទានិសិទ្ធិរបស់ខ្លួន

7. ចុងបញ្ចប់ អំណះអំណាងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ទាក់ទងនឹងថាតើហេតុអ្វីបានជាសំណុំរឿងប្រឆាំងនឹង យឹម ទិត្យ គួរត្រូវបានបដិសេធចោលនោះ ខកខានមិនបានបង្ហាញថា ដីកាសម្រេចរបស់ ស.ច.ស.អ នោះមិនត្រឹមត្រូវយ៉ាងខ្លាំង ឬមិនសមហេតុផលយ៉ាងខ្លាំង ដែលបង្កើតបានជាការបំពានលើឆន្ទានុសិទ្ធិ[24]។ អំណះអំណាងនីមួយៗទាំងនេះ ត្រូវបានលើកឡើងម្តងមួយៗខាងក្រោមនេះ។

---

[23] ជាឧទាហរណ៍ បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ មិនបានជំទាស់ទៅនឹងការកឃើញដែលថា យឹម ទិត្យ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានា រួមមាន អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មជាច្រើនទៀតប្រឆាំងនឹងមនុស្សជាតិ នៅតាមជាង ២០ ទីតាំង (*សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៩៩៥) ដែលគាត់បានចូលរួមចំណែកនៅក្នុងនោះ និងការសម្របសម្រួលឲ្យមានអំពើប្រល័យពូជសាសន៍លើពួកខ្មែរក្រោមនៅតាមកន្លែងនានាដែលគាត់ទទួលខុសត្រូវដែល "អង្គហេតុនេះតែមួយគត់ក៏អាចដាក់គាត់យ៉ាងជាប់មិនឲ្យរួចខ្លួនពីយុត្តាធិការបុគ្គលនោះទេ" (*សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៩៩៦), ថាជនស៊ីវិលដទៃទៀត និង អតីតកម្មាភិបាល ប.ក.ក ដែលបានរងគ្រោះនៅក្រោម និងដោយ យឹម ទិត្យ ដែលត្រូវបានរាប់ជាចំនួនអស់ជាច្រើនពាន់នាក់ (*សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៩៩៧), ឬក៏ថា យឹម ទិត្យ និងជនទាំងឡាយដែលគាត់សហការជាមួយ បានដាក់ពួកបុរស និងស្ត្រី "ចំពោះការពិសោធន៍សង្គមដែលគួរឲ្យខ្ពើមរបស់ ប.ក.ក" នៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមសង្វាសអាពាហ៍ពិពាហ៍ដែល "បានបំផ្លាញជីវិតមនុស្សខ្មែរជាច្រើននាក់ និងអស់រយៈពេលជាច្រើនទសវត្សរ៍" (*សូមមើល* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៩៩៨)។

[24] *សូមមើល ជាឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Orić*, MICT-14-79 សេចក្តីសម្រេចលើពាក្យសុំប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ចៅក្រមតែម្នាក់ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ៩។ *រដ្ឋអាជ្ញា ទល់នឹង Uwinkindi*, ICTR-01-75-AR72(C) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចបដិសេធញត្តិដែលលើកឡើងចោទប្រកាន់ពីវិការៈនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ កថាខណ្ឌ ៦។ *រដ្ឋអាជ្ញា ទល់នឹង Gotovina និងគូកន*, IT-06-90-AR73.1 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់ Miroslav Šeparović ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំ

## ខ. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ បានអះអាងពីនិយមន័យនៃយុត្តាធិការបុគ្គល ដោយមិនគិតពី ចេតនាដែលបានបញ្ជាក់របស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប

8. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ បានកត់សម្គាល់យ៉ាងត្រឹមត្រូវថា អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅក្រោមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប ("កិច្ចព្រមព្រៀង អ.វ.ត.ក" ឬ "កិច្ចព្រមព្រៀង") និងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ច្បាប់ អ.វ.ត.ក")[25]។ លិខិតុប្បករណ៍ទាំងពីរនេះបានផ្តល់យុត្តាធិការដែលមានកម្រិតចំពោះមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានា និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ទម្លាប់អន្តរជាតិ ហើយនឹងអនុសញ្ញាអន្តរជាតិនានាដែលប្រទេសកម្ពុជាបានទទួលស្គាល់[26]។ យ៉ាងណាក៏ដោយ បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ បានអះអាងដោយខុសឆ្គងថាការបន្តសំណុំរឿងប្រឆាំងនឹង យឹម ទិត្យ នឹងពង្រីកវិសាលភាពនៃយុត្តាធិការបុគ្គលដោយ មិនត្រឹមត្រូវ ពីព្រោះថា "គំនិតរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះកិច្ចព្រមព្រៀង អ.វ.ត.ក" គឺថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រូវបានកម្រិតត្រឹមតែមេដឹកនាំជាន់ខ្ពស់មួយចំនួនតូច ហើយថា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" "គឺសំដៅតែ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ដែលជាប្រធានមន្ទីរសន្តិសុខ ស-២១ *តែម្នាក់គត់*"[27]។ និយមន័យនៃយុត្តាធិការបុគ្គលបែបដូច្នេះ មិនគិតពីចេតនាដែលបានបញ្ជាក់របស់រាជរដ្ឋាភិបាលកម្ពុជា និងរបស់ អ.ស.ប នៅពេលដែលមានកិច្ចព្រមព្រៀងនោះទេ។

---

ជម្រះសាលាដំបូងស្តីពីទំនាស់ផលប្រយោជន៍ និងការកឃើញនូវការប្រព្រឹត្តមិនត្រឹមត្រូវ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ ១១។ *រដ្ឋអាជ្ញា ទល់នឹង* S. Milošević, IT-02-54-AR73.7 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំ ទៅនឹងសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចាត់តាំងមេធាវីការពារក្តី អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ ១០។

[25] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៦០។ *សូមមើល* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងកំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក" ឬ "កិច្ចព្រមព្រៀង")។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ("ច្បាប់ អ.វ.ត.ក") ដោយបូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦)។

[26] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១។ ច្បាប់ អ.វ.ត.ក មាត្រា ១។

[27] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ កថាខណ្ឌ ៦៦ (សង្កត់ន័យបន្ថែម និងការសង្កត់ន័យចោល), ៧២។

9. ទោះជា ស.ព.អ ឯកភាពថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រូវបានកម្រិតនោះ ក៏ ស.ព.អ ជំទាស់ថា មានតែ ឌុច ទេ ដែលត្រូវបានកំណត់ថាជាប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះ។ ការបកស្រាយបែបដូច្នេះមិនត្រូវបានគាំទ្រដោយពាក្យពេជន៍នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក នោះទេ ដោយឯកសារទាំងពីរនេះបានប្រើសព្វនាម "*ជនទាំងឡាយ* ដែលទទួលខុសត្រូវខ្ពស់បំផុត"[28]។ តាមរយៈការសរសេរជាទម្រង់ពហុវចនៈ ចំណុចនេះបានយោងយ៉ាងជាក់ច្បាស់ទៅដល់ *ប្រភេទ* នៃក្រុមមនុស្ស មិនមែន មនុស្សតែម្នាក់ទេ។ អត្ថបទនៃកិច្ចព្រមព្រៀង អ.វ.ត.ក ត្រូវបានសន្និដ្ឋានថាជាការបញ្ជាក់ពីចេតនារបស់ភាគីទាំងពីរនៃសន្ធិសញ្ញានោះ គឺរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប[29]។ ប្រសិនបើភាគីទាំងនោះមានការយល់ដឹងថា ឌុច គឺជា "អ្នកទទួលខុសត្រូវបំផុត" តែម្នាក់ សម្រាប់គោលបំណងនៃការកាត់សេចក្តីនៅ អ.វ.ត.ក នោះនោះពួកគាត់បានចែងច្បាស់នៅក្នុងកិច្ចព្រមព្រៀងរបស់ពួកគាត់ ដែលពេលនោះ រាជរដ្ឋាភិបាល

---

[28] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១ (សង្កត់ន័យបន្ថែម)។ ច្បាប់ អ.វ.ត.ក មាត្រា ១, ២ថ្មី (សង្កត់ន័យបន្ថែម)។ ភាសាជាពហុវចនៈនេះ កើតមានឡើងនៅក្នុងសំណៅជាបីភាសាទាំងអស់ (ខ្មែរ អង់គ្លេស និង បារាំង) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក។ សំណៅជាភាសាខ្មែរ បញ្ជាក់ថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" និងសំណៅជាភាសា បារាំង បានយោងថា "les principaux responsables"។

[29] អនុសញ្ញាទីក្រុងវីយ៉ែនស្តីពីច្បាប់សន្ធិសញ្ញា ចុះថ្ងៃទី២៣ ខែឧសភា ១៩៦៩ ("អនុសញ្ញាទីក្រុងវីយ៉ែន") 1155 UNTS 331 មាត្រា ៣១(១) ("សន្ធិសញ្ញាគួរត្រូវបានបកស្រាយដោយសុទ្ធចិត្ត យោងតាមអត្ថន័យធម្មតាដែលបានផ្តល់នៅក្នុងពាក្យពេចន៍នានានៃសន្ធិសញ្ញានោះនៅក្នុងបរិបទរបស់ពួកវា និង ដោយទាក់ទងនឹងប្រធានបទ និងគោលបំណងរបស់វា")។ ភាគីនានាបានព្រមព្រៀងយ៉ាងជាក់ច្បាស់ថា អនុសញ្ញាទីក្រុងវីយ៉ែននេះអនុវត្តចំពោះកិច្ចព្រមព្រៀង អ.វ.ត.ក (*សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(២))។ *សូមមើល ផងដែរ ជម្លោះនៃដែនដី (Libyan Arab Jamahiriya ទល់នឹង ប្រទេសឆាដ)* សាលក្រម ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៩៤ របាយការណ៍របស់ ICJ ឆ្នាំ១៩៩៤ ទំព័រទី ៦ កថាខណ្ឌ ៤១ ("ការបកស្រាយត្រូវតែមានមូលដ្ឋានពីលើអ្វីៗទាំងអស់ នៅលើអត្ថបទនៃសន្ធិសញ្ញា")។ *នីត្យានុកូលភាពនៃការប្រើប្រាស់កម្លាំង (ប្រទេសស៊ែប៊ី និងម៉ុងតេណេក្រូ ទល់នឹង ប្រទេសបែលហ្ស៊ិក)* អញ្ញត្រកម្ម សាលក្រម ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៤ របាយការណ៍របស់ ICJ ឆ្នាំ២០០៤ ទំព័រទី ២៧៩ កថាខណ្ឌ ១០០។ *ការបកស្រាយច្បាប់សន្ធិសញ្ញាសន្តិភាព ជាមួយនឹង ប្រទេសប៊ុលហ្គារី ប្រទេសហុងគ្រី និង ប្រទេសរូម៉ានី (ដំណាក់កាលទីពីរ)* មតិយោបល់ប្រឹក្សា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៥០ របាយការណ៍របស់ ICJ ឆ្នាំ១៩៥០ ទំព័រទី ២២១, ទំព័រទី ២២៩ ("វាជាករណីយកិច្ចរបស់តុលាការក្នុងការបកស្រាយសន្ធិសញ្ញា មិនមែនពិនិត្យសារឡើងវិញនោះទេ")។ ពង្រាងមាត្រានានានៃ ILC ស្តីពីច្បាប់សន្ធិសញ្ញាដោយមានសេចក្តីអត្ថាធិប្បាយ *សៀវភៅប្រចាំឆ្នាំនៃគណៈកម្មាធិការច្បាប់អន្តរជាតិ* ឆ្នាំ១៩៦៦ វ៉ុលុម II ទំព័រទី ២២០ កថាខណ្ឌ ១១ ("សេចក្តីអត្ថាធិប្បាយមាត្រា ២៧ [ឥឡូវនេះ មាត្រា ៣១]៖ ដូចដែលបានបញ្ជាក់រួចហើយ មាត្រានេះគឺមានមូលដ្ឋាននៅលើទស្សនៈដែលថា អត្ថបទត្រូវតែបានសន្មតថាជា ឃ្លាយថាភូត នៃចេតនារបស់ភាគីនានា ហើយថាជាផលវិបាក ចំណុចចាប់ផ្តើមនៃការបកស្រាយគឺការបំភ្លឺពីអត្ថន័យនៃអត្ថបទ មិនមែនជាការស៊ើបអង្កេត*ពីដើមដំបូង (ab initio)* ទៅលើចេតនារបស់ភាគីនានានោះឡើយ។ វិទ្យាស្ថានច្បាប់អន្តរជាតិបានអនុម័តវិធីសាស្ត្រ - ពាក្យឬឃ្លាដើម - នៃការបកស្រាយសន្ធិសញ្ញានេះ")។

កម្ពុជាត្រូវអនុវត្តច្បាប់ អ.វ.ត.ក។ អត្ថបទនៃកិច្ចព្រមព្រៀង អ.វ.ត.ក លើកឡើងច្បាស់ថា ពួកគាត់មិនថែងដូច្នោះទេ។

10. ជាងនេះទៀត ផ្ទុយទៅនឹងការអះអាងដែលថា រាជរដ្ឋាភិបាលកម្ពុជាមានបំណងថា អ្នកទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" សំដៅ "*តែ*" ទៅលើ ឧុច[30] នោះ រាជរដ្ឋាភិបាលកម្ពុជាឯកភាពថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" អាចជាប្រភេទបើកចំហ ដែលសមាជិកភាពរបស់ពួកគេអាចត្រូវបានកំណត់ដោយតុលាការតែប៉ុណ្ណោះ។ ចំណុចនេះមានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា ក្នុងអំឡុងពេលកិច្ចចរចាកិច្ចព្រមព្រៀង អ.វ.ត.ក។ ឧទាហរណ៍ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសជាសាធារណៈទៅកាន់ព្រឹទ្ធសមាជិក ស.រ.អ John Kerry ថា ជនណាដែល អ.វ.ត.ក សម្រេចថាចោទប្រកាន់ និងផ្តន្ទាទោស នឹងអាស្រ័យទាំងស្រុងលើតុលាការនេះ ហើយគាត់បានសន្យាថា រាជរដ្ឋាភិបាលនឹងមិនជ្រៀតជ្រែកកិច្ចដំណើរការនីតិវិធី អ.វ.ត.ក ទោះក្នុងវិធីណាក៏ដោយ[31]។

---

[30] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍ ស.ព.ជ កថាខណ្ឌ៦៦ (គូសបញ្ជាក់បន្ថែម)។

[31] ឯកសារ **D324.22** លិខិតចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ ពីលោកនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ទៅកាន់លោកអគ្គលេខា UN Doc. A/53/875, S/1999/324, ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩ EN 01326021, កថាខណ្ឌ ២-៣ ("រាជរដ្ឋាភិបាលកម្ពុជាមិនមានអំណាចអ្វីដើម្បីដាក់កម្រិតអ្វីទៅលើតុលាការមិនសមត្ថកិច្ច ធ្វើតាមនោះទេ។ [...] បញ្ហាថាតើត្រូវកាត់ទោស តាម៉ុកតែម្នាក់ឯង ឬមេដឹកនាំខ្មែរក្រហមដទៃទៀត អាស្រ័យទាំងស្រុងលើតុលាការមានសមត្ថកិច្ច។ រាជរដ្ឋាភិបាលកម្ពុជា នឹងមិនប្រើប្រាស់ឥទ្ធិពលណាមួយ ឬជ្រៀតជ្រែកក្នុងទម្រង់ណាក៏ដោយ ទៅក្នុងកិច្ចដំណើរការនីតិវិធីធម្មតារបស់តុលាការដែលនឹងទទួលបានឯករាជភាពពេញលេញ ពីអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ។"។ *កត់សម្គាល់* ថាក្នុងកថាខណ្ឌ ៤ លោក ហ៊ុន សែន បានស្នើថា លិខិតនេះត្រូវផ្សព្វផ្សាយជាឯកសារមហាសន្និបាត។ ឯកសារ **D324.23** សេចក្តីថ្លែងធ្វើឡើងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៩៩ ដោយខុទ្ទកាល័យសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា UN Doc. S/1999/443, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៩ EN 01326023 កថាខណ្ឌ ២ ("ការបញ្ជូនរឿងទៅជំនុំជម្រះ និងការចោទប្រកាន់ពួកមេដឹកនាំខ្មែរក្រហម គឺជាសមត្ថកិច្ចតែមួយគត់របស់តុលាការ។ រាជរដ្ឋាភិបាលមិនមានសិទ្ធិក្នុងការផ្តល់បញ្ជាឲ្យទៅផ្នែកតុលាការថាត្រូវធ្វើនេះ ឬធ្វើនោះទេ។")។ *សូមមើលផងដែរ* សារព័ត៌មាន Kyodo News International, *ហ៊ុន សែន សោកស្តាយដែលបានលើកឡើងពីចំនួនមេដឹកនាំខ្មែរក្រហមត្រូវកាត់ទោស* ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០០ (នៅក្នុងបទសម្ភាសន៍ជាមួយសារព័ត៌មានជប៉ុន៖ "លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីប្រទេសកម្ពុជាបានបញ្ជាក់ពីការសោកស្តាយកាលពីថ្ងៃសុក្រ ដោយបានថ្លែងថា មេដឹកនាំខ្មែរក្រហម "បួន ទៅប្រាំ" នាក់នឹងត្រូវបានដាក់ឲ្យកាត់ទោស [...]។ គាត់បាននិយាយថា 'ខ្ញុំមិនត្រូវធ្វើអត្ថាធិប្បាយអ្វីលើរឿងនេះទេ ឬក៏និយាយអ្វីនៅក្នុងដែនកំណត់របស់តុលាការទេ'។ [...] លោក ហ៊ុន សែន បាននិយាយថា បុគ្គលណាមួយដែលបាននិយាយឲ្យច្បាស់លាស់ពីចំនួនមេដឹកនាំដែលត្រូវកាត់ទោស 'គឺខុសហើយ ហើយថារឿងនោះមានរួមទាំងអ្នកជំនាញច្បាប់របស់ អ.ស.ប ផងដែរ ដែលបានពោលថាមានមនុស្ស ២០ ឬ ៣០ នាក់។' លោកនាយករដ្ឋមន្ត្រីបាននិយាយថា ដោយការផ្តល់នូវចំនួនជាក់លាក់មួយពីមេដឹកនាំខ្មែរក្រហមដែលត្រូវកាត់ទោសគឺ 'យើងបានបំពានលើតុលាការមួយដែលប្រើច្បាប់'")។

11. ដូចដែលបានកត់សម្គាល់យ៉ាងត្រឹមត្រូវដោយ សពជ ការកំណត់យក “ចំនួនជនដែលត្រូវនាំយកមកកាត់ទោសដ៏តិចតួចនេះ” ត្រូវបាន “ជជែកវែកញែកគ្នាយ៉ាងតឹងតែង” ក្នុងពេលប្រជុំរដ្ឋសភា[32] ដែលបានធ្វើឡើងភ្លាមៗមុនពេលរដ្ឋសភាអនុម័តកិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា ក្នុងខែតុលា ឆ្នាំ២០០៤។ ច្បាស់ណាស់ ការពិភាក្សាដេញដោលនេះបានប្រកាសយ៉ាងច្បាស់ថា មិនមានចំនួនជាក់លាក់ ឬបញ្ជីមនុស្សដែលត្រូវបានកំណត់អត្តសញ្ញាណសម្រាប់ការបញ្ជូនខ្លួនទៅជំនុំជម្រះទេ ដោយសារថា នេះគឺជាកិច្ចការរបស់ អ.វ.ត.ក[33]។ សពអ សន្និដ្ឋានថា សេចក្ដីថ្លែងការណ៍ដែលឧបនាយករដ្ឋមន្ត្រី សុខ អាន (ដែលបានដឹកនាំកិច្ចចរចាសម្រាប់រាជរដ្ឋាភិបាលកម្ពុជា) បានធ្វើឡើងទៅកាន់រដ្ឋសភាជាតិ ក្នុងពេលកិច្ចពិភាក្សាដេញដោយនេះ ផ្ដល់ជាភ័ស្ដុតាងដ៏ល្អបំផុតអំពីចេតនារបស់រដ្ឋាភិបាលកម្ពុជានៅពេលកិច្ចព្រមព្រៀងនេះ។ ច្បាស់ណាស់ ប្រតិចារឹកនៃកិច្ចពិភាក្សាដេញដោលបង្ហាញថា អ្នកតែងច្បាប់របស់រដ្ឋាភិបាលជាច្រើននាក់បានស្នើសុំការបញ្ជាក់ពីអ្វីដែលអ្នកធ្វើសេចក្ដីព្រាងចង់មានន័យចំពោះពាក្យថា “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត”៖

> ឯ.ឧ. លី ធុច៖ “ប្រជាជនយើង និងសង្គមស៊ីវិល ចង់សុំឲ្យឯកឧត្តម សុំបញ្ជាក់ឲ្យបានច្បាស់ថា តើនរណាខ្លះជាមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត? តើពួកគេរាប់បញ្ចូលទាំងប្រធានអង្គភាពរបស់អង្គការដែរ ឬទេ?[34]
>
> ឯ.ឧ. កែវ រ៉េមី៖ “តើនរណាខ្លះជាមេដឹកនាំជាន់ខ្ពស់? [...] តើប្រធានភូមិភាគត្រូវកាត់ទោសដែរឬទេ? ឬមួយថា ច្បាប់នេះគ្រាន់តែ [បាន] ធ្វើឡើងដើម្បីកាត់ទោសមេដឹកនាំ ៤ ឬ ៥ នាក់ប៉ុណ្ណោះ។ តើមាននរណាខ្លះទៀតដែលនឹងត្រូវកាត់ទោសដែរ? វាមិនមានយុត្តិធម៌ទេ បើយើងកាត់ទោសតែ ៣ ឬ ៤ នាក់ នោះ”[35]។
>
> ឯ.ឧ. អេង ឆៃអ៊ាង៖ “ខ្ញុំក៏មិនច្បាស់ដែរចំពោះពាក្យ *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ តើជនទាំងនោះត្រូវទទួលខុសត្រូវប៉ុនណា? [...] ខ្ញុំចង់ឲ្យអ្នកតំណាងរដ្ឋាភិបាលធ្វើការបញ្ជាក់ថា ទំហំប៉ុនណាដែលពួកជនទាំងនោះត្រូវទទួលខុសត្រូវធំបំផុតនោះ។ [...] ខ្ញុំសូមរំឭកថា សូមកុំឲ្យប្រជាជនស្រពិចស្រពិល។ ប្រសិនបើ

---

[32] ឯកសារ **D382/4/1** បណ្ដឹងឧទ្ធរណ៍ ស.ព.ជ កថាខណ្ឌ៦៧។

[33] ឯកសារ **D378/5.1.2** ប្រតិចារឹកបកប្រែដោយ DC-Cam អំពីសម័យប្រជុំលើកទីមួយ នៃរដ្ឋសភាកម្ពុជា ថ្ងៃទី៤-៥ ខែតុលា ឆ្នាំ២០០៤ (“ប្រតិចារឹករដ្ឋសភាជាតិ”) EN 01593392-93។

[34] ឯកសារ **D378/5.1.2** ប្រតិចារឹករដ្ឋសភាជាតិ EN 01593371។

[35] ឯកសារ **D378/5.1.2** ប្រតិចារឹករដ្ឋសភាជាតិ EN 01593376។

យើងសង្កត់ធ្ងន់លើតែថ្នាក់ខ្ពស់បំផុត យើងចង់មានន័យថា ប៉ុល ពត ដែលបានស្លាប់បាត់ហើយនោះ”[36]។

12. សុខ អាន បានឆ្លើយថា៖

> បើសិនជាយើងសួរសំណួរថា “តើនរណាខ្លះនឹងត្រូវចោទប្រកាន់?” គឺទាំងអង្គការសហប្រជាជាតិ ទាំងក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជា មិនអាចផ្តល់ចម្លើយបានទេ។ ពីព្រោះរឿងនេះជាកិច្ចការរបស់តុលាការ៖ គឺអង្គជំនុំជម្រះវិសាមញ្ញ។ បើសិនជាយើងធ្វើបញ្ជីឈ្មោះមនុស្សសម្រាប់ការកាត់ទោសជំនួសតុលាការ នោះយើងបំពានលើអំណាចរបស់តុលាការ។ ដូច្នេះ យើងមិនអាចកំណត់អត្តសញ្ញាណថា ក, ខ, គ ឬ ឃ ជាអ្នកដែលត្រូវចោទប្រកាន់បានទេ។ ជាដំណោះស្រាយ យើងបានកំណត់អត្តសញ្ញាញក្រុមគោលដៅចំនួនពីរ៖ *មេដឹកនាំជាន់ខ្ពស់* និង *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ ចំពោះ *មេដឹកនាំជាន់ខ្ពស់* យើងសំដៅទៅលើមនុស្សមិនលើសពី ១០នាក់ទេ ក៏ប៉ុន្តែយើងមិននិយាយឲ្យច្បាស់ថា អ្នកទាំងនោះជាសមាជិកគណៈអចិន្ត្រៃយ៍។ រឿងនេះគឺជាកិច្ចការរបស់សហព្រះរាជអាជ្ញា ដែលត្រូវសម្រេចថានរណាខ្លះជាមេដឹកនាំជាន់ខ្ពស់។ [...] យ៉ាងណាក៏ដោយ វានៅតែមានក្រុមគោលដៅទីពីរទៀត។ ពួកគាត់មិនមែនជាមេដឹកនាំទេ ក៏ប៉ុន្តែពួកគេបានប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ។ ព្រោះហេតុនោះហើយបានជាយើងប្រើពាក្យថា *ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*។ <u>វាមិនមានចំនួនមនុស្សជាក់លាក់នៅក្នុងក្រុមទីពីរនេះដែលត្រូវបានចោទប្រកាន់នោះទេ</u>[37]។

13. ចំពោះទស្សនៈរបស់ អ.ស.ប វិញ ក្រុមអ្នកជំនាញដែលត្រូវបានចាត់តាំងដោយលោកអគ្គលេខាធិការ ដើម្បីស្វែងរកជម្រើសដែលនាំមកនូវយុត្តិធម៌ប្រសើរបំផុត បានថ្លែងក្នុងឆ្នាំ១៩៩៩ ថា៖

> ក្រុមនោះផ្តល់អនុសាសន៍ថា ការផ្តោតរបស់តុលាការទៅលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សក្នុងអំឡុងពេលកាន់កាប់របស់កម្ពុជាប្រជាធិបតេយ្យ។ ចំណុចនេះ រាប់បញ្ចូលទាំងមេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវចំពោះការរំលោភបំពាន ក៏ដូចជាជនទាំងឡាយនៅថ្នាក់ក្រោមដែលត្រូវបានជាប់ទាក់ទងផ្ទាល់នៅក្នុងអំពើឃោរឃៅធ្ងន់ធ្ងរបំផុត។ <u>យើងមិនចង់ផ្តល់នូវការកម្រិតតួលេខលើចំនួនមនុស្សបែបនោះ ដែលអាចត្រូវបានផ្តោតគោលដៅ</u>

[36] ឯកសារ **D378/5.1.2** ប្រតិចារឹករដ្ឋសភាជាតិ EN 01593389។

[37] ឯកសារ **D378/5.1.2** ប្រតិចារឹករដ្ឋសភាជាតិ EN 01593392-93 (គូសបញ្ជាក់បន្ថែម)។

សម្រាប់ការស៊ើបអង្កេតនោះទេ។ យ៉ាងណាក៏ដោយ វាគឺជាការគិតរបស់ក្រុមនោះតាមរយៈការពិគ្រោះយោបល់ និងការស្រាវជ្រាវរបស់ខ្លួនថា ចំនួនមនុស្សដែលត្រូវកាត់ទោស អាចស្ថិតនៅចន្លោះពី២០ ទៅ ៣០នាក់[38]។

14. អនុសាសន៍ទាំងនេះបង្កើតបានជាមូលដ្ឋានសម្រាប់គោលជំហរចរចារបស់ អ.ស.ប។ លោក David Shcheffer ដែលជាអគ្គរដ្ឋទូតគោចររបស់ ស.រ.អ សម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម និងដែលបានចូលរួមយ៉ាងច្រើននៅក្នុងការចរចានេះ[39] បានរំឭកនៅក្នុងអត្ថបទបោះពុម្ពផ្សាយមួយក្នុងឆ្នាំ២០១១ ថា អ្នកចរចា អ.ស.ប លោក Ralph Zacklin បានមកធ្វើទស្សនកិច្ចទីក្រុងភ្នំពេញក្នុងចុងខែសីហា ឆ្នាំ១០៩៩ និងបានចាកចេញជាមួយនឹងចំណាប់អារម្មណ៍ថា អាជ្ញាធរកម្ពុជាចង់កាត់ទោសតែ តាម៉ុក និង ឌុច តែប៉ុណ្ណោះ ប៉ុន្តែគោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជា *បានផ្លាស់ប្តូរ* ខណៈពេលដែលការចរចាបានដំណើរការជឿនលឿនទៅមុខ ក្នុងរយៈពេលសេសសល់នៃឆ្នាំ ១៩៩៩ និង ២០០០[40]។ អត្ថបទនេះបានរៀបរាប់លម្អិតអំពីការចូលរួមពាក់ព័ន្ធផ្ទាល់ខ្លួនរបស់លោក Scheffer ក្នុងការចរចានេះ ជាពិសេសទាក់ទងនឹងការពិចារណាទាក់ទងនឹង ឌុច និង ប្រភេទ "ទទួលខុសត្រូវខ្ពស់បំផុត"[41]។ គាត់បានសរសេរថា "យើងគ្រាន់តែចាប់អារម្មណ៍ទៅលើពួកមេដឹកនាំជាន់ខ្ពស់ដែលនៅរស់រានមានជីវិត ដែលបានបង្ហាញពីការទទួលខុសត្រូវដ៏សំខាន់ *ក៏ដូចជាពួកមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀត ដូចជា ឌុច* ដែលមានតួនាទីដ៏សំខាន់បែបនេះនៅក្នុងអំពើឃោរឃៅ"[42]។ ច្បាស់ណាស់ ការយល់ឃើញរបស់ អ.ស.ប គឺថា ប្រភេទនោះមិនត្រូវកម្រិតត្រឹមតែ ឌុច នោះទេ។

---

[38] ឯកសារ **D324.15** របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា បានធ្វើឡើងស្របតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៥២/១៣៥ ឯកសាររបស់ អ.ស.ព លេខ A/53/850, S/1999/231 ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ ("របាយការណ៍ក្រុមអ្នកជំនាញ អ.ស.ប") កថាខណ្ឌ១១០ (គូសបញ្ជាក់បន្ថែម)។

[39] ឯកសារ **D378/5.1.205** Scheffer, D., *ប្រវត្តិនៃការចរចាស្តីពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក* Cambodia Tribunal Monitor ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១ ("អត្ថបទរបស់ Scheffer") EN 01595691 ("ការចូលរួមផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងដំណើរការចរចា ទាំងដើម្បីតំណាងឲ្យផលប្រយោជន៍ ស.រ.អ និងដើម្បីបម្រើជាសន្ទានការី*តាមព្រឹត្តិន័យ* រវាងអ្នកចារចាកម្ពុជា និង អ.ស.ប"។

[40] ឯកសារ **D378/5.1.205** អត្ថបទរបស់ Scheffer EN 01595691។

[41] ឯកសារ **D378/5.1.205** អត្ថបទរបស់ Scheffer ជាពិសេស EN 01595691-93។

[42] ឯកសារ **D378/5.1.205** អត្ថបទរបស់ Scheffer EN 01595693 (គូសបញ្ជាក់បន្ថែម ហើយការគូសបញ្ជាក់ក្នុងច្បាប់ដើមត្រូវបានដកចេញ)។

15. នៅខែមីនា ឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានស្នើឡើងពាក្យថា "ជនទាំងឡាយដែលទទួលខុសត្រូវ" ដែលបានពង្រីកប្រភេទនេះលើសពីអ្វីដែល អ.ស.ប ធ្លាប់លើកឡើង ហើយលោកអគ្គលេខាធិការ អ.ស.ប Kofi Annan និង ទីប្រឹក្សាច្បាប់របស់ អ.ស.ប លោក Hans Corell ទាំងពីរនាក់បានបញ្ជាក់ពីកង្វល់យ៉ាងច្បាស់លាស់ទៅកាន់រដ្ឋាភិបាលកម្ពុជាថា ឥឡូវនេះក្រុមនោះមានភាពទូលាយពេក[43]។ នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជាបានអនុម័តសេចក្តីព្រាងច្បាប់ អ.វ.ត.ក ដោយមានពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវ*ខ្ពស់បំផុត*"[44]។ ជាការគួរឱ្យកត់សម្គាល់ Scheffer មិនបានចាំថា នៅក្នុងពេលចរចា មាន "ការធ្វើសម្បទានដោយអ្នកចរចារបស់ អ.ស.ប ក្នុងការបកស្រាយពីពាក្យស្តីពីយុត្តាធិការបុគ្គល ដើម្បីកម្រិតក្រុមជនសង្ស័យឱ្យនៅត្រឹមតែបុគ្គលជាក់លាក់ចំនួនប្រាំនាក់នោះទេ"[45]។

16. សរុបសេចក្តីមក ប្រវត្តិនៃការចរចារបស់ អ.វ.ត.ក បង្ហាញថា ទាំងចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា និងរបស់ អ.ស.ប នៅពេលធ្វើកិច្ចព្រមព្រៀង អ.វ.ត.ក គឺថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាប្រភេទបើកចំហ ដោយសមាជិកភាពរបស់ពួកគេត្រូវបានកំណត់ដោយសហព្រះរាជអាជ្ញា និងចៅក្រមនៃ អ.វ.ត.ក តែប៉ុណ្ណោះ ដោយផ្អែកទៅលើភស្តុតាងទាំងមូល និងបំពេញកិច្ចដោយឯករាជ្យ មិនស្ថិតក្រោមការណែនាំណាមួយឡើយ។ ការបកស្រាយនេះត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសាលដីកាលើបណ្តឹងសាទុក្ខរបស់ខ្លួនក្នុងសំណុំរឿង ០០១[46] និងត្រូវបានបញ្ជាក់ដោយសហចៅក្រមស៊ើបអង្កេតទាំងពីរនៅក្នុងដីកាដំណោះ

---

[43] ឯកសារ **D378/5.1.205** អត្ថបទរបស់ Scheffer EN 01595693-96។

[44] ឯកសារ **D378/5.1.205** អត្ថបទរបស់ Scheffer EN 01595696 (គូសបញ្ជាក់បន្ថែម)។

[45] ឯកសារ **D378/5.1.205** អត្ថបទរបស់ Scheffer EN 01595698។

[46] សំណុំរឿង០០១-ឯកសារ **F28** សាលដីកាបណ្តឹងសាទុក្ខ *ឌុច* កថាខណ្ឌ៦២-៨១ ជាពិសេស កថាខណ្ឌ៦២ ("ការកំណត់ថាតើជនជាប់ចោទជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរ ឬយ៉ាងណា តម្រូវឱ្យមានការប្រើឆន្ទានុសិទ្ធិយ៉ាងច្រើន") កថាខណ្ឌ៦៣ ("ពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គប្បីត្រូវបានបកស្រាយថា ជាគោលការណ៍ណែនាំនៃការចោទប្រកាន់ និងការស៊ើបអង្កេតសម្រាប់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ដែលមិនអាចធ្វើការវិនិច្ឆ័យនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។") កថាខណ្ឌ៧០ ជើងទំព័រ១៣៣ ("ដោយហេតុថា ពាក្យពេចន៍ "ទទួលខុសត្រូវខ្ពស់បំផុត" មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក [ប៉ុន្តែមានតម្លៃស្មើទៅនឹងគោលការណ៍ណែនាំនាំការចោទប្រកាន់ និងស៊ើបអង្កេត] ដូច្នេះ ជនត្រូវចោទមិនអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបានឡើយ ដោយអនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨) ដោយមូលហេតុថា ខ្លួនពុំស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ពីព្រោះខ្លួនមិនមែន "ទទួលខុសត្រូវខ្ពស់បំផុត"" អវត្តមានការរំលោភលើឆន្ទានុសិទ្ធិ។)។

ស្រាយនៃសំណុំរឿង០០៤/១ និងដោយ ស.ច.ស.ជ នៅក្នុងដីសម្រេចលើកលែងចោទប្រកាន់របស់គាត់ក្នុងសំណុំរឿង០០៤/២ និង សំណុំរឿង ០០៤[47]។

## គ. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ខកខានមិនបានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាមានអំណាចក្នុងការកម្រិតយុត្តាធិការបុគ្គលដោយឯកតោភាគី

17. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ បានទទួលស្គាល់ដោយប្រយោលថា សេចក្តីថ្លែងរបស់រាជរដ្ឋាភិបាលកម្ពុជាមានបំណងដាក់កម្រិតយុត្តាធិកាបុគ្គល អ.វ.ត.ក ប៉ុន្តែ លើកឡើងថា កិច្ចខិតខំប្រឹងប្រែងទាំងនេះគ្រាន់តែជា "ការដើរតួ" របស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលក្រុមប្រឹក្សាសន្តិសុខ អ.ស.ប បានធ្វើជាមួយតុលាការ ICTY, ICTR, និង SCSL តែប៉ុណ្ណោះ[48]។ បន្ទាប់មក បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ជំរុញឲ្យ អ.ប.ជ អនុវត្តកិច្ចស្របតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមស្មារតីនៃច្បាប់ អ.វ.ត.ក ស្តីពីយុត្តាធិការបុគ្គល[49]។

18. បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ផ្អែកអំណះអំណាងនេះលើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥០៣ និង ១៥៣៤ ដែលត្រូវបានអនុម័តប្រមាណ ១០ឆ្នាំ ក្រោយការបង្កើតតុលាការ ICTY និងតុលាការ ICTR និងទាក់ទងទៅនឹងផែនការបញ្ចប់របស់តុលាការពីរនេះ[50]។ សេចក្តីសម្រេចទាំងពីរនេះបង្គាប់ឲ្យតុលាការ ICTY និង តុលាការ ICTR ផ្តោតកិច្ចប្រឹងប្រែង

---

[47] សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ៣៧។ សំណុំរឿង០០៤/២ -ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ៤៦១។ សំណុំរឿង០០៣- ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ៣៦៤។ ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ៦០៣។

[48] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍ ស.ព.ជ កថាខណ្ឌ ៦៥។

[49] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍ ស.ព.ជ កថាខណ្ឌ ៦៥។

[50] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍ ស.ព.ជ កថាខណ្ឌ ៦២។ ទោះបីជាអត្ថបទនៃកថាខណ្ឌ ៦២ យោងទៅលើសេចក្តីសម្រេចចិត្តលេខ ២០០៤ របស់ក្រុមប្រឹក្សាសន្តិសុសក៏ដោយ ក៏ជើងទំព័រពាក់ព័ន្ធបញ្ជាក់ច្បាស់ថា លេខត្រឹមត្រូវនៃសេចក្តីសេចក្តីសម្រេចចិត្តគឺលេខ ១៥៣៤។ ជាងនេះទៀត សេចក្តីសម្រេចចិត្តលេខ ២០០៤ ទាក់ទងទៅនឹងការពង្រីកអាណាត់របស់កងកម្លាំងបណ្តោះអាសន្នរបស់ អ.ស.ប ក្នុងប្រទេសលីបាណន់ (UNIFIL) មិនទាក់ទងទៅនឹងតុលាការ ICTY, ICTR ឬផែនការបញ្ចប់របស់ពួកគេឡើយ។ *សូមមើល* ឯកសារ **D378/5.1.12** សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥០៣ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣ ("សេចក្តីសម្រេចចិត្តលេខ ១៥០៣") S/RES/1503 (២០០៣)។ ឯកសារ **D378/5.1.13** សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥៣៤ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ ("សេចក្តីសម្រេចចិត្តលេខ ១៥៣៤") S/RES/1534 (២០០៤)។ សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ២០០៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ S/RES/2004 (២០១១)។

របស់ខ្លួនទៅលើ "មេដឹកនាំជាន់ខ្ពស់ ដែលសង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម" និងបញ្ជូនសំណុំរឿងផ្សេងទៀតទៅយុត្តាធិការជាតិ ដើម្បីសម្រេចតាមផែនការបញ្ចប់របស់តុលាការ[51]។ តាមរយៈចំណុចនេះ បណ្ដឹងឧទ្ធរណ៍របស់ ស.ព.ជ បានសន្និដ្ឋានដោយភាន់ច្រឡំថា "រាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជាស្ថាបនិកមួយនៃកិច្ចព្រមព្រៀង អាចមានឥទ្ធិពលលើដំណើរការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" និងថា "ការកម្រិតវិសាលភាពយុត្តាធិការបុគ្គល" គឺជា "វិធីសាស្ត្រដែលអាចទទួលយកបានសម្រាប់ការបញ្ចប់អាណត្តិរបស់អង្គជំនុំជម្រះនេះ" ពីព្រោះ វិធីសាស្ត្រនេះត្រូវបានប្រើនៅក្នុងតុលាការ ICTY និង ICTR[52]។

19. នេះគឺជាការប្រៀបធៀបមិនត្រឹមត្រូវទេ។ តុលាការ ICTY និងតុលាការ ICTR ត្រូវបានបង្កើតឡើងពីដំបូងដោយសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ[53] ហើយនៅក្នុងការអនុម័តយកតាមសេចក្ដីសម្រេចលេខ ១៥០៣ និង ១៥៣៤ ទាក់ទងនឹងផែនការបញ្ចប់ ក្រុមប្រឹក្សាសន្តិសុខបានឆ្លងកាត់ដំណើរការដូចគ្នានេះ ដោយមានកិច្ចធានាដំណើរការនីតិវិធីតែមួយដូចគ្នាទាំងអស់ដូចដែលមាននៅពេលបង្កើតជាតុលាការ*មិនអចិន្ត្រៃយ៍*ទាំងនេះពីដំបូង។ សមាជិកទាំងអស់នៃក្រុមប្រឹក្សាសន្តិសុខមានសិទ្ធចូលរួមនៅក្នុងកិច្ចពិភាក្សាដេញដោលលើសេចក្ដីសម្រេចលេខ ១៥០៣ និង ១៥៣៤ និងផ្ដល់យោបល់លើអង្គសេចក្ដីនៃការផ្លាស់ប្ដូរយុទ្ធសាស្ត្រជ្រើសរើសសំណុំរឿងរបស់តុលាការ។ សមាជិកម្នាក់ៗនៃក្រុមប្រឹក្សាសន្តិសុខ នៅពេលនោះមានសិទ្ធិបោះឆ្នោតលើសេចក្ដីសម្រេចដែលបានដាក់ស្នើឡើង មុនពេលត្រូវបានអនុម័ត។ ជាក់ស្ដែង បើសិនជាសមាជិកណាតែម្នាក់នៃក្រុមប្រឹក្សាសន្តិសុខបានបង្ហាញទស្សនៈថា តុលាការ*មិនអចិន្ត្រៃយ៍* នេះគួរផ្លាស់ប្ដូរយុទ្ធសាស្ត្រជ្រើសរើសសំណុំរឿងរបស់ខ្លួន ដើម្បីឱ្យមានអានុភាពណាមួយនោះ ជាដំបូងគួរតែឆ្លងកាត់ដំណើរការពិភាក្សាដេញដោល និងមានការបោះឆ្នោតមួយដើម្បីអនុម័តសេចក្ដីសម្រេចជាផ្លូវការ។

20. ក្នុងករណី អ.វ.ត.ក នេះ ការប្រៀបធៀបដ៏សមស្របទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខដែលបានបង្កើតតុលាការ*មិនអចិន្ត្រៃយ៍* នោះ គឺកិច្ចព្រមព្រៀង អ.វ.ត.ក ដែលត្រូវបានអនុម័ត

---

[51] ឯកសារ **D378/5.1.12** សេចក្ដីសម្រេចចិត្តលេខ ១៥០៣ EN 01593497-98។ ឯកសារ **D378/5.1.13** សេចក្ដីសម្រេចចិត្តលេខ ១៥៣៤ កថាខណ្ឌ ៤-៥។

[52] ឯកសារ **D382/4/1** បណ្ដឹងឧទ្ធរណ៍ ស.ព.ជ កថាខណ្ឌ៦១។

[53] ឯកសារ **D378/5.1.10** សេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨២៧ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ S/RES/827 (១៩៩៣) (ការបង្កើតតុលាការ ICTY)។ ឯកសារ **D378/5.1.11** សេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៩៥៥ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ S/RES/955 (១៩៩៤) (ការបង្កើតតុលាការ ICTR)។

ដោយ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីការចរចារដែលនៅក្នុងនោះភាគីទាំងពីរគឺជាសមភាគី។ កិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា "នៅក្នុងករណីចាំបាច់មានវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិសោធនកម្មនេះត្រូវតែមានការពិគ្រោះយោបល់គ្នាជាមុនរវាងភាគីទាំងពីរ"[54]។ បទប្បញ្ញត្តិនេះបញ្ជាក់ច្បាស់ថា ការកែប្រែណាមួយក្នុងគោលនយោបាយពាក់ព័ន្ធនឹងបញ្ហានានាដែលបានលើកឡើងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក (ដែលរួមទាំង យុត្តាធិការបុគ្គលផង) ត្រូវតែអនុម័តដោយភាគី *ទាំងពីរ* តាមរយៈកិច្ចពិភាក្សា ដែលក្នុងនោះភាគី*ទាំងពីរ*ចូលរួម។ មកទល់ពេលនេះ ទាំងរាជរដ្ឋាភិបាលកម្ពុជា ឬ អ.ស.ប. មិនបានស្នើឲ្យមានការកែប្រែបទប្បញ្ញត្តិទាក់ទងនឹងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក នេះទេ។ ហេតុដូច្នេះ វិសាលភាពនៃយុត្តាធិការបុគ្គលដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក កំណត់យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ហើយគឺជាច្បាប់ដែលអង្គបុរេជំនុំជម្រះត្រូវតែអនុវត្ត។

21. ការទទួលស្គាល់សិទ្ធិរបស់ អ.ស.ប ក្នុងការចូលរួមកែប្រែគោលនយោបាយស្តីពីយុត្តាធិការបុគ្គលមិនបានធ្វើឲ្យប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជានោះទេ។ រដ្ឋទាំងឡាយមានអំណាចចូលរួមក្នុងកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត ហើយការដែលបានធ្វើដូច្នោះ រដ្ឋនីមួយៗ គិតចាប់ពីរដ្ឋធំបំផុតដល់រដ្ឋតូចបំផុត មានកាតព្វកិច្ចអនុវត្តតាមកិច្ចព្រមព្រៀង លុះត្រាតែ និងរហូតទាល់តែ ត្រូវបានធ្វើវិសោធនកម្ម ឬរដ្ឋនោះដកខ្លួនចេញជាផ្លូវការ។ ក្រោយពីបានផ្តល់សច្ចាប័នកិច្ចព្រមព្រៀង អ.វ.ត.ក ភាគីទាំងពីរជាប់កាតព្វកិច្ចដោយលក្ខខណ្ឌរបស់កិច្ចព្រមព្រៀងនេះ ហើយមិនមានភាគីណាមួយអាចកែប្រែអត្ថន័យនៃលក្ខខណ្ឌទាំងនោះតាមរយៈសេចក្តីប្រកាសគោលនយោបាយជាឯកតោភាគីធ្វើឡើងក្រោយពេលអនុម័តកិច្ចព្រមព្រៀងនេះបានឡើយ[55]។ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាលែងមានបំណងផ្តល់ការទទួលខុសត្រូវឲ្យ អ.វ.ត.ក នាំយកជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកជំនុំជម្រះ រដ្ឋាភិបាលនេះអាចស្នើសុំដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ[56] ឬធ្វើវិសោធនកម្មច្បាប់ អ.វ.ត.ក ដោយមានការឯកភាពពី អ.ស.ប។ មិនមានការព្យាយាមណាមួយត្រូវបានធ្វើឡើងដើម្បីធ្វើដូច្នេះឡើយមកទល់ពេលនេះ។

---

[54] កិច្ចព្រមព្រៀប អ.វ.ត.ក មាត្រា ២(៣)។

[55] ជាការទ្បូត វាច្បាស់ណាស់ថា ប្រសិនបើមន្ត្រី អ.ស.ប បានលើកឡើងថា ពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" ឧទាហរណ៍រួមមាន កម្មាភិបាលខ្មែរក្រហមណាមួយនៅក្នុងកម្រិតណាមួយ ដែលបានសម្លាប់មនុស្សលើសពី ២៥នាក់ ចំណុចនេះនឹងមិនមែនជាមូលដ្ឋានដ៏គួរឲ្យជឿជាក់សម្រាប់ការអះអាងថា នោះគឺជានិយមន័យត្រឹមត្រូវនៃពាក្យនេះឡើយ លុះត្រាតែរាជរដ្ឋាភិបាលកម្ពុជាក៏បានឯកភាពផងដែរ ហើយភាគីទាំងពីរបានធ្វើវិសោធនកម្មច្បាប់ អ.វ.ត.ក។

[56] អនុសញ្ញាទីក្រុងវីយែន មាត្រា ៥៤, ៥៦។

22. ខុសពី “ឥទ្ធិពល” របស់រាជរដ្ឋាភិបាលកម្ពុជា “លើដំណើរការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា”[57] សេចក្តីសម្រេចលេខ ១៥០៣ និង ១៥៣៤ មិនមានន័យថាមានឥទ្ធិពលណាមួយលើបញ្ហាថាតើ សំណុំរឿងមួយត្រូវបានចោទប្រកាន់ ឬយ៉ាងណានោះទេ ផ្ទុយទៅវិញ សេចក្តីសម្រេចទាំងនេះមានឥទ្ធិពលតែទៅលើតុលាការដែលជំនុំជម្រះសំណុំរឿងជាក់លាក់នោះប៉ុណ្ណោះ។ សេចក្តីសម្រេចលេខ ១៥០៣ បានណែនាំឱ្យតុលាការ*មិនអចិន្ត្រៃយ៍* ឱ្យផ្តោតលើសំណុំរឿងប្រឆាំងនឹង “មេដឹកនាំជាន់ខ្ពស់ ដែលសង្ស័យថាជាជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត” ប៉ុន្តែ សំណុំរឿងផ្សេងទៀតមិនត្រូវបានច្រានចោលទេ ផ្ទុយទៅវិញ ត្រូវ “ផ្ទេរ [បានផ្ទេរ] [...] ទៅតុលាការជាតិដែលមានសមត្ថកិច្ច”[58]។ តាមពិតនោះ ក្រុមប្រឹក្សាសន្តិសុខបានបញ្ជាក់ថា ការអនុម័តសេចក្តីសម្រេចលេខ ១៥០៣ មិនមានបំណងកាត់បន្ថយចំនួនមនុស្សដែលត្រូវស៊ើបអង្កេត និងជំនុំជម្រះចំពោះឧក្រិដ្ឋកម្មឃោរឃៅក្នុងទ្រង់ទ្រាយធំទេ សេចក្តីសម្រេចនេះចែងយ៉ាងច្បាស់ថា ផែនការបញ្ចប់របស់តុលាការ “មិនត្រូវប៉ះពាល់ដល់កាតព្វកិច្ចរបស់ប្រទេសរ៉្វាន់ដា និងប្រទេសទាំងឡាយនៃអតីតយូហ្គោស្លាវី ក្នុងការស៊ើបអង្កេតជនជាប់ចោទទាំងនោះ ដែលសំណុំរឿងរបស់ពួកគេមិនត្រូវបានជំនុំជម្រះដោយតុលាការ ICTR ឬតុលាការ ICTY និងត្រូវចាត់វិធានការសមស្របទាក់ទងនឹងការបញ្ជូនរឿងទៅជំនុំជម្រះ និងការកាត់ទោស”[59]។ សេចក្តីសម្រេចលេខ ១៥០៣ និង ១៥៣៤ មិនលើកទឹកចិត្តឱ្យមាននិទណ្ឌភាពចំពោះឧក្រិដ្ឋកម្មស្ថិតក្រោមយុត្តាធិការតុលាការ*មិនអចិន្ត្រៃយ៍* នោះទេ ផ្ទុយទៅវិញ គ្រាន់តែបែងចែកកិច្ចការស៊ើបអង្កេតនិងការចោទប្រកាន់រវាងតុលាការ *មិនអចិន្ត្រៃយ៍* និងតុលាការជាតិប៉ុណ្ណោះ។

23. អ្វីដែលសំខាន់បំផុត ក្រុមប្រឹក្សាសន្តិសុខបានគោរពចំពោះឯករាជ្យភាពរបស់តុលាការតាមរយៈការមិនបញ្ចេញទស្សនៈណាមួយទៅលើការសម្រេចសេចក្តីដែលសមស្របនៃករណីណាមួយ តាមបណ្តាតុលាការ ICTY ឬ ICTR ឡើយ។ ទោះបីជាក្រុមប្រឹក្សានេះ *បាន* កំណត់អំពីលក្ខណវិនិច្ឆ័យចំពោះ “មេដឹកនាំជាន់ខ្ពស់បំផុតដែលសង្ស័យថា មានការទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានា” ចំពោះលក្ខខណ្ឌសាកល្បងនៃករណីដែលត្រូវរក្សាទុកក៏ដោយ ក៏ក្រុមប្រឹក្សានេះមិនដែលបញ្ចេញមតិយោបល់អំពីថាតើ ករណីណាមួយបានបំពេញលក្ខណវិនិច្ឆ័យទាំងនោះឡើយ[60]។ ការប្រើលក្ខខណ្ឌសាកល្បងនេះ ត្រូវបានរក្សាទុកឱ្យធ្វើការសម្រេច ទៅតាមឆន្ទានុសិទ្ធិ

[57] ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍ ស.ព.ជ កថាខណ្ឌ៦១។

[58] ឯកសារ **D378/5.1.12** សេចក្តីសម្រេចចិត្តលេខ ១៥០៣ EN 01593497-98។

[59] ឯកសារ **D378/5.1.12** សេចក្តីសម្រេចចិត្តលេខ ១៥០៣ EN 01593498។

[60] ឯកសារ **D378/5.1.12** ដំណោះស្រាយលេខ ១៥០៣, EN 01593497។

ឯករាជ្យរបស់ចៅក្រមនៃតុលាការ ICTY និង ICTR ទាំងស្រុង ដោយពួកគាត់បានជ្រើសរើសបញ្ជូនករណីខ្លះទៅតុលាការជាតិ ក្នុងខណៈដែលពួកគាត់សម្រេចថា ករណីខ្លះទៀតជាការល្អបំផុតដែលត្រូវធ្វើការចោទប្រកាន់នៅតុលាការ *មិនអចិន្ត្រៃយ៍*។

24. ទាំងកិច្ចព្រមព្រៀង អ.វ.ត.ក និងទាំងច្បាប់ អ.វ.ត.ក សុទ្ធតែតម្រូវឲ្យចៅក្រម អ.វ.ត.ក អនុវត្តឆន្ទានុសិទ្ធិដោយឯករាជ្យដូចគ្នានេះដោយសេរី។ មួយផ្នែកនៃមាត្រា ១០*ថ្មី* នៃច្បាប់ អ.វ.ត.ក ចែងថា "ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពមួយផ្សេងទៀតឡើយ"។ ការហាមឃាត់ចៅក្រមពីការទទួលយកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពមួយផ្សេងទៀត ក៏មានបង្ហាញនៅក្នុងមាត្រា ៣(៣) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ផងដែរ។

25. លក្ខខណ្ឌតម្រូវសម្រាប់អំណាចតុលាការឯករាជ្យ ក៏មានឆ្លុះបញ្ចាំងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា[61] និងលិខិតុបករណ៍សិទ្ធិមនុស្សជាច្រើន និងសេចក្តីថ្លែងការណ៍ស្តីពីការអនុវត្តល្អ និងបទដ្ឋានអប្បបរមាផងដែរ។ ចំណុចទាំងនេះរួមមាន សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងស្តីពីគោលការណ៍ឯករាជ្យភាពរបស់តុលាការ ដែលបានប្រកាសឲ្យប្រើដោយសមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក[62] គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ ដែលត្រូវបានអនុមតិដោយមហាសន្និបាតអង្គការសហប្រជាជាតិ[63] និងក្រមទីក្រុងញូដេលីស្តីពីបទដ្ឋានអប្បបរមានៃឯករាជ្យភាពរបស់តុលាការ ដែលបានអនុមតិដោយគណៈមេធាវីអន្តរជាតិ[64]។ ចំណុចទាំងនេះគឺជាការដាក់

---

[61] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, អនុមតិនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងច្បាប់វិសោធនកម្មនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩, មាត្រា ៥១ ("អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។"), មាត្រា ១២៨ (មុនមាត្រា ១០៩) ("អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ"), មាត្រា ១២៩ (មុនមាត្រា ១១០) ("មានតែចៅក្រមទេ ដែលមានសិទ្ធិជំរះក្តី"), មាត្រា ១៣០ (មុនមាត្រា ១១១) ("គ្មានអង្គការណាមួយ នៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ")។

[62] សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងស្តីពីគោលការណ៍ឯករាជ្យភាពនៃអំណាចតុលាការនៅក្នុងតំបន់ឡាអេសៀ សមាគមអ្នកច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក, ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៧ ("គោលការណ៍ទីក្រុងប៉េកាំង"), មាត្រា ៣(ក), មាត្រា ៤-៥។

[63] គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពនៃអំណាចតុលាការ ដែលបានអនុមតិតាមរយៈសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៤០/៣២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និង លេខ ៤០/១៤៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥ ("គោលការណ៍ជាមូលដ្ឋាន"), កថាខណ្ឌ ១-២, ៤។

[64] ក្រមទីក្រុងញូដេលីស្តីពីបទដ្ឋានអប្បបរមានៃឯករាជ្យភាពតុលាការ, គណៈមេធាវីអន្តរជាតិ, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៨២ ("ក្រមទីក្រុងញូដេលី"), មាត្រា ១៦។

ភារកិច្ចមួយដល់ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀតឲ្យគោរព និងធ្វើតាមឯករាជ្យភាពតុលាការ និងរារាំងការដាក់សម្ពាធទោះក្នុងទម្រង់ណាក៏ដោយទៅលើចៅក្រម[65]។

26. ជាចុងក្រោយ គោលការណ៍ជាមូលដ្ឋាននៃនិតិរដ្ឋ មានន័យថា ថ្វីបើអង្គនីតិប្បញ្ញត្តិ ឬអង្គនីតិប្រតិបត្តិ មានការទទួលខុសត្រូវចំពោះ*ការបង្កើតច្បាប់* តាមរយៈនីតិកម្ម បទបញ្ជារបស់អង្គនីតិប្រតិបត្តិ និងសិទ្ធិសញ្ញាផ្សេងៗក៏ដោយ មានតែតុលាការប៉ុណ្ណោះដែលជាអ្នកសម្រេចអំពី*របៀបអនុវត្តច្បាប់*ចំពោះករណីនីមួយៗ។ ក្នុងប្រព័ន្ធមួយដែលបានគ្រប់គ្រងដោយនិតិរដ្ឋ ឯករាជ្យភាពរបស់តុលាការត្រូវបានគោរព។ ចៅក្រមត្រូវសម្រេចសេចក្ដីរបស់ខ្លួនដោយផ្អែកលើច្បាប់ ភ័ស្ដុតាង ហើយការសម្រេច និងសម្បជញ្ញៈផ្ទាល់ខ្លួន គ្មានការទទួលយកការបង្គាប់បញ្ជាពីរដ្ឋាភិបាល ឬពីប្រភពខាងក្រៅណាមួយឡើយ។

## ឃ. ដំណោះស្រាយតាមផ្លូវតុលាការដោយឯករាជ្យចំពោះសំណុំរឿង ០០៣, ០០៤ និង ០០៤/២ នឹងលើកកម្ពស់ទាំងយុត្តិធម៌ និងការផ្សះផ្សា

27. បណ្ដឹងឧទ្ធរណ៍របស់ ស.ព.ជ អះអាងថា បុព្វកថានៃកិច្ចព្រមព្រៀង អ.វ.ត.ក តម្រូវឲ្យ "គិតគូអំពីតុល្យភាពរវាង "យុត្តិធម៌" និង "ការបង្រួបបង្រួមជាតិ" ដោយអះអាងថា សំណុំរឿង ០០១ និង ០០២ បាននាំមកនូវយុត្តិធម៌ដល់ជនរងគ្រោះរួចហើយ និងចង់បង្កប់ន័យថា ការបន្តកិច្ចដំណើរការនីតិវិធីប្រឆាំង យឹម ទិត្យ នឹងធ្វើឲ្យខូចដល់ការបង្រួបបង្រួមជាតិ[66]។ ទោះជាយ៉ាងណា បណ្ដឹងឧទ្ធរណ៍របស់ ស.ព.ជ មិនបានផ្ដល់ភ័ស្ដុតាងណាមួយដែលថា ការនាំខ្លួន យឹម ទិត្យ ទៅទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនានាដែលគាត់ត្រូវបានចោទប្រកាន់ នឹងធ្វើឲ្យខូចដល់ការបង្រួបបង្រួមជាតិតាមផ្លូវណាមួយ នោះឡើយ។ ផ្ទុយទៅវិញ ច្បាស់ណាស់ថា ការធ្វើឲ្យ យឹម ទិត្យ ទៅឆ្លើយនៅសវនាការលើភ័ស្ដុតាងសំខាន់ៗជាច្រើនអំពីតួនាទីរបស់គាត់ ដែលមាននៅក្នុងឧក្រិដ្ឋកម្មទាំងនោះ ដែលប៉ះពាល់ដល់ប្រជាជនកម្ពុជារាប់ម៉ឺននាក់ នឹងជួយធ្វើឲ្យសម្រេចបានវិធានការខ្លះនៃយុត្តិធម៌សម្រាប់ជនរងគ្រោះបន្ថែមទៀត ដូច្នេះជួយដោះស្រាយកង្វល់នៅក្នុងបុព្វកថា។

28. ទីមួយ សំខាន់យើងត្រូវកត់សំគាល់ថា ក្រុមអ្នកជំនាញរបស់ អ.ស.ប ស្ដីពីកម្ពុជា បានលើកឡើងនៅក្នុងរបាយការណ៍របស់ខ្លួនជូនអគ្គលេខាធិការក្នុងឆ្នាំ១៩៩៩ ថា "គណនីយភាពសម្រាប់អតីតកាល និងការបង្រួបបង្រួមជាតិសម្រាប់អនាគត គឺ [...] មិនមែនជាគោលដៅដែលមានជាមួយ

---

[65] *សូមមើល* គោលការណ៍ទីក្រុងប៉េកាំង, មាត្រា ៣(ក), មាត្រា ៤-៥។ គោលការណ៍ជាមូលដ្ឋាន, កថាខណ្ឌ ១-២, ៤។ ក្រមទីក្រុងញូដេលី, មាត្រា ១៦, ១៨។

[66] ឯកសារ **D382/4/1** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.ជ, កថាខណ្ឌ ៧០-៧២។

គ្នាទេ ឬសូម្បីតែជាការប្រកួតប្រជែងគ្នាទេ។ [...] ប្រសិនបើយុត្តិធម៌ត្រូវបាននាំយកដោយវិចារណញ្ញាណចំពោះស្ថានភាពរបស់ប្រទេសផ្ទាល់ ពិតណាស់ថា គណនីយភាព និងការបង្រួបបង្រួមជាតិគឺជាការបង្គ្រប់យ៉ាងបរិបូរណ៍ ដែលស្ទើរតែមិនអាចបំបែកបាន"[67]។ តាមពិត សេចក្តីសម្រេចលេខ ៥៧/២២៨ របស់មហាសន្និបាត អ.ស.ប ទទួលស្គាល់ថា "គណនីយភាពរបស់ចារីម្នាក់ៗចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ គឺជាធាតុផ្សំមជ្ឈិមមួយនៃឧបាស្រ័យដ៏មានប្រសិទ្ធិភាពសម្រាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស ហើយជាកត្តាគន្លឹះមួយក្នុងការធានាឲ្យបាននូវប្រព័ន្ធយុត្តិធម៌ដែលត្រឹមត្រូវ និងស្មើភាព ដែលជាចុងក្រោយ នាំឲ្យមានការបង្រួបបង្រួម និងស្ថេរភាពនៅក្នុងរដ្ឋមួយ"[68]។

29. ទីពីរ និយាយយ៉ាងសាមញ្ញ គេគ្មានសញ្ញាណអ្វីទាំងអស់ដែលថា ដំណោះស្រាយតាមផ្លូវតុលាការដោយឯករាជ្យចំពោះសំណុំរឿង ០០៤/២, ០០៤ និង ០០៣ លើអង្គសេចក្តីនានា ទោះបីដំណោះស្រាយនោះបែបណាក៏ដោយ នឹងគំរាមកំហែងដល់សន្តិភាព និងសន្តិសុខរបស់កម្ពុជាឡើយ។ ដូច ស.ព.អ បានធ្វើការសង្កេតកន្លងមកដែរ ដំណោះស្រាយក្នុងសំណុំរឿង ០០១ និង ០០២ ដែលមានការកាត់ទោស និងការដាក់ទោសរហូតអស់មួយជីវិត មិនបានធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ការបង្រួបបង្រួមជាតិ និងសន្តិភាពទេ។ ផ្ទុយទៅវិញ ការកាត់ទោសទាំងនេះទទួលបានការសរសើរមិនដាច់ពីមាត់ទាំងនៅក្នុង និងខាងក្រៅកម្ពុជា ហើយទំនងជា*បានលើកកម្ពស់* ដល់ការផ្សះផ្សាផង[69]។ ករណីទាំងនេះពាក់ព័ន្ធនឹងជនជាប់ចោទទាំងសិទ្ធិអំណាចដែលស្ថិតក្រោម យឹម ទិត្យ(ឌុច) និងទាំងថ្នាក់លើរបស់គាត់នៅក្នុងឋានានុក្រម បកក(នួន ជា និង ខៀវ សំផន)។ លើសពីនេះទៀត គ្មានប្រតិកម្មអវិជ្ជមានជាសាធារណៈចំពោះការប្រកាសថា យឹម ទិត្យ អោ អាន និង មាស មុត ត្រូវបានចោទប្រកាន់ដោយ ស.ច.ស.អ ទេ ហេតុដូច្នេះ គ្មានមូលហេតុដែលនាំឲ្យជឿថា ការបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះនឹងនាំឲ្យមានការគំរាមកំហែងដល់ការផ្សះផ្សាជាតិឡើយ។ លើសពីនេះទៀត បច្ចុប្បន្ន កម្ពុជាកំពុងតែរីករាយក្នុងការទទួលបានសុខសន្តិភាព និងស្ថេរភាពដែលបានកើតមានជាងពីរទសវត្សរ៍មកហើយ[70]។ គ្មានក្រុមប្រដាប់អាវុធណាមួយកំពុងតែអនុវត្តអំណាច

---

[67] ឯកសារ **D324.15** របាយការណ៍របស់ក្រុមអ្នកជំនាញ អ.ស.ប, កថាខណ្ឌ ៣។

[68] ឯកសារ **D324.34** ដំណោះស្រាយ លេខ ៥៧/២២៨ ដែលបានអនុមតិដោយមហាសន្និបាតអង្គការសហប្រជាជាតិ អំពីការការកាត់សេចក្តីខ្មែរក្រហម, ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣, EN 01326103។

[69] ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង យឹម ទិត្យ, ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ"), កថាខណ្ឌ ១១៥១។

[70] សូម្បីតែក្នុងឆ្នាំ១៩៩៨ ក្នុងអំឡុងនៃទស្សនកិច្ចរបស់ក្រុមអ្នកជំនាញដើម្បីកម្ពុជា សមាជិកនៃសាធារណជនកម្ពុជា និងសមាជិករដ្ឋាភិបាលមិនបានបញ្ជាក់អំពីការគាំទ្រចំពោះអាទិភាពដាច់ខាតនៃបញ្ហាសន្តិសុខនៅលើផលប្រយោជន៍នៃយុត្តិធម៌ទេ។ ដូចក្រុម

នៅលើទឹកដីរបស់កម្ពុជាឡើយ។ ខ្មែរក្រហមត្រូវបានបញ្ឈប់ និងលែងជាអង្គការនយោបាយ ឬយោធាណាមួយទៀត ហើយអតីតកម្មាភិបាលរបស់អង្គការនេះ ក៏ចាស់ៗអស់ហើយដែរ ចំណែករបប ប៉ុល ពត ត្រូវបានថ្កោលទោសស្ទើរតែជាសកល ហើយយើងគ្មានភស្តុតាងគាំទ្រណាមួយដល់ការងើបឡើងវិញនៃចលនានេះទេ[71]។

30. ផ្ទុយទៅវិញ មានសញ្ញាណច្បាស់នានាបង្ហាញថា ជនរងគ្រោះមិនយល់ស្របជាមួយនឹងការអះអាងដែលថា លែងត្រូវការយុត្តិធម៌បន្ថែមនោះទេ បន្ទាប់ពីសវនាការជំនុំជម្រះក្នុងសំណុំរឿង00១ និង 00២[72]។ ចាប់តាំងពីការបង្កើត អ.វ.ត.ក មក ការសិក្សាជាច្រើនពាក់ព័ន្ធនឹងគោលគំនិតរបស់សាធារណជនកម្ពុជាអំពី អ.វ.ត.ក ត្រូវបានបោះពុម្ពផ្សាយ។ ខណៈការសិក្សាទាំងនេះមានវិធីសាស្ត្រ ក្រុមគោលដៅ និងសំណួរស្រាវជ្រាវខុសៗគ្នាក៏ពិតមែន តែការសិក្សាទាំងអស់បង្ហាញថា សាធារណជនកម្ពុជាមានចំណាប់អារម្មណ៍យ៉ាងខ្លាំង ចង់ឃើញរឿងក្តីនានាដែលនៅសេសសល់បន្តដំណើរទៅមុខ។

31. ការសិក្សាថ្មីបំផុតត្រូវបានគេបោះពុម្ពផ្សាយក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ហើយការសិក្សានេះត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលម៉ាប៊ឺកសម្រាប់ការសិក្សាអំពីជម្លោះ (Marburg Centre for Conflict Studies) មជ្ឈមណ្ឌលភ្នំពេញសម្រាប់ការសិក្សាអំពីច្បាប់មនុស្សធម៌ (Phnom Penh Centre for the Study of Humanitarian Law) និង Swisspeace (ការសិក្សារបស់ម៉ាប៊ឺក - "Marburg Study")[73]។ ការសិក្សាទាំងនេះផ្តោតលើការចូលរួមរបស់ជនរងគ្រោះ ដោយស្ទាបស្ទង់មតិលើជនរងគ្រោះនៃរបបខ្មែរក្រហមចំនួន ៤៣៩នាក់ ដែលពួកគេត្រូវបានធ្វើការជ្រើសរើសដោយចោះៗពី

អ្នកជំនាញបានសង្កេតឃើញថា "ទាក់ទងនឹងមតិសាធារណជន ក្រុមពិតជាបានឮអំពីចំណង់ដ៏ខ្លាំងមួយក្នុងចំណោមប្រជាជនកម្ពុជាទាំងនៅក្នុង និងខាងក្រៅរដ្ឋាភិបាល ដែលចង់បានសន្តិភាព។ ប៉ុន្តែ គ្មាននរណាម្នាក់បានឲ្យដឹងថា សន្តិភាព និងការជំរះក្តីមិនអាចផ្សះផ្សាបាននោះទេ ឬក៏ថា ប្រជាជនកម្ពុជាបានមើលឃើញថាសន្តិភាពអាចជំនួសយុត្តិធម៌ បានក៏ទេដែរ"។ *សូមមើល* ឯកសារ **D324.15** របាយការណ៍របស់ក្រុមអ្នកជំនាញ អ.ស.ប, កថាខណ្ឌ ១០០។

[71] ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ, កថាខណ្ឌ ១១៥៣។

[72] *ផ្ទុយទៅនឹង* ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ, កថាខណ្ឌ ៧២។

[73] Williams, T. និងគូកន., *យុត្តិធម៌ និងការផ្សះផ្សាសម្រាប់ជនរងគ្រោះខ្មែរក្រហម? ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការយុត្តិធម៌អន្តរកាលរបស់កម្ពុជា,* ម៉ាប៊ឺក: មជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីជម្លោះ។ ភ្នំពេញ: មជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីច្បាប់មនុស្សធម៌អន្តរជាតិ។ Bern: swisspeace, ខែវិច្ឆិកា ឆ្នាំ២០១៨ ("ការសិក្សារបស់ម៉ាប៊ឺក")។ ការប្រមូលទិន្នន័យសម្រាប់ការសិក្សា បានចាប់ផ្តើមតាំងពីថ្ងៃទី២៩ ខែមករា រហូតដល់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ (*សូមមើល* ការសិក្សារបស់ម៉ាប៊ឺក, ទំព័រ ២៣)។

ក្រុមចំនួនបួនដែលគេបានកំណត់ជាមុន[74]។ អ្វីដែលគួរឲ្យកត់សំគាល់គឺនៅពេលសួរថាតើ អ.វ.ត.ក គួរតែដោះស្រាយចំពោះសំណុំរឿង ០០៣ និង ០០៤ (រួមទាំងសំណុំរឿង០០៤/២ ផង) ដែរឬអត់នោះ ចំនួនអ្នកឆ្លើយ ៨០.២ភាគរយ ចង់ឲ្យសំណុំរឿងទាំងនេះបន្តដំណើរទៅមុខ[75]។ មូលហេតុចម្បងចំនួនប្រាំត្រូវបានលើក ពីច្រើនទៅតិចបំផុត គឺ (i) តើវានឹងផ្តល់ដល់អ្នកឆ្លើយនឹងសំណួរនូវយុត្តិធម៌ដែរឬទេ? (ii) តើវាមានន័យយុត្តិធម៌ដល់ជនរងគ្រោះជាទូទៅដែរឬទេ? (iii) តើវាមានន័យថា មេដឹកនាំខ្មែរក្រហមមិនអាចគេចពីយុត្តិធម៌ដែរឬទេ? (iv) តើវានឹងផ្តល់ការជឿជាក់បន្ថែមអំពីរបបខ្មែរក្រហមដែរឬទេ? និង (v) តើវានឹងផ្តល់យុត្តិធម៌ដល់កម្ពុជាដែរឬទេ?[76] អ្នកឆ្លើយនឹងសំណួរតែ ២.៧៧ ភាគរយប៉ុណ្ណោះជឿថា សំណុំរឿងទាំងនេះ មិនគួរបន្តនីតិវិធីទៅមុខដោយសារវានឹងបង្កឲ្យមានជម្លោះនោះ[77]។

32. អង្គការ Open Society Justice Initiative បានដឹកនាំការសិក្សាមួយពីខែតុលា ឆ្នាំ២០១៣ ដល់ខែមករា ឆ្នាំ២០១៤ ("ការសិក្សារបស់ OSJI") ដែលផ្តោតអំពីផលប៉ះពាល់របស់ អ.វ.ត.ក ទៅលើប្រជាជនកម្ពុជាធម្មតា[78]។ ទំហំសំណាកនៃអ្នកឆ្លើយនឹងសំណួរដែលបានធ្វើសម្ភាសន៍ មានទំហំតូចជាងការសិក្សារបស់ម៉ាប៊ឹក ប៉ុន្តែមានភាពចម្រុះច្រើនជាង ដែលរួមមានទាំង ជនរងគ្រោះ/អ្នកនៅ

---

[74] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក មានសមាសភាពក្នុងក្រុមទីមួយ ដែលមានចំនួនជាងពាក់កណ្តាលនៃអ្នកឆ្លើយ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ត្រូវបានបែងចែកជាប្រាំបីអនុក្រុម ដែលមានកម្រិតនៃការចូលរួមខុសៗគ្នានៅក្នុងកិច្ចដំណើរការនីតិវិធី និងមានខ្លះជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៣ និង០០៤ (សំណុំរឿង០០៤ ត្រូវបានប្រើជាពាក្យដែលគ្របដណ្តប់ក្រោមឆត្រតែមួយ ដែលរួមបញ្ចូលទាំងសំណុំរឿង ០០៤/២ ផង)។ ក្រុមទីពីរ គឺជាសមាសភាពនៃអ្នកប្តឹង (មានន័យថា គឺជាបុគ្គលនានាដែលបានចុះបញ្ជីជាមួយតុលាការ ដោយសារពួកគេបានផ្តល់ព័ត៌មានផ្សេងៗ ប៉ុន្តែពួកគាត់អត់ដាក់ពាក្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទេ។ ក្រុមទីបី គឺមានសមាសភាពនៃជនរងគ្រោះដែលបានចូលរួមនៅក្នុងសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ទាក់ទងនឹងយុត្តិធម៌អន្តរកាលនៅកម្ពុជា។ ក្រុមទីបួន គឺជាក្រុមដែលរួមមានបុគ្គលនានាដែលមិនធ្លាប់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក និងគំរោងអង្គការមិនមែនរដ្ឋាភិបាលដូច្នេះទេ។ ក្នុងចំណោមអ្នកឆ្លើយទាំងអស់ មានអ្នកឆ្លើយតែពីរនាក់គត់ដែលបានពិចារណាថា ខ្លួនគេជាជនរងគ្រោះនៃរបបខ្មែរក្រហម ហើយវ័យជាមធ្យមរបស់អ្នកឆ្លើយ គឺ ៦២.៤ឆ្នាំ។ *សូមមើល* ការសិក្សារបស់ម៉ាប៊ឹក, ទំព័រ ១៩, ២២-២២, ២៨។

[75] ការសិក្សារបស់ម៉ាប៊ឹក, ទំព័រ ៦២។

[76] ការសិក្សារបស់ម៉ាប៊ឹក, ទំព័រ ៦៣ *កត់សំគាល់* ថាអ្នកឆ្លើយត្រូវបានអនុញ្ញាតឲ្យផ្តល់ចម្លើយច្រើន។

[77] ការសិក្សារបស់ម៉ាប៊ឹក, ទំព័រ ៦២-៦៣។ មានតែ ១៤% ក្នុងចំណោមអ្នកឆ្លើយ ១៩.៨% ដែលមិនគាំទ្រសំណុំរឿង ០០៣ និង ០០៤ ប៉ុណ្ណោះបានលើកយោងនូវមូលហេតុនេះ គឺស្មើនឹងតែ ២.៧៧%ប៉ុណ្ណោះនៃក្រុមអ្នកឆ្លើយទាំងអស់។

[78] Ryan, H. និង McGrew, L., *ការប្រព្រឹត្ត និងផ្នត់គំនិត: ផលប៉ះពាល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,* ញូយ៉ក: Open Society Justice Initiative, ឆ្នាំ២០១៦ ("ការសិក្សារបស់ OSJI") ទំព័រ ១២៦-១២៧, en. 210។

រស់រានមានជីវិត ចារីដែលបានចោទប្រកាន់ អ្នកនៅជិតកន្លែងកើតហេតុ និងយុវជន[79]។ ក្នុងពេលដែលទិន្នន័យត្រូវបានប្រមូល ក្នុងចំណោមអ្នកឆ្លើយនឹងសំណួរចំនួន ៤៩នាក់ ដែលត្រូវបានសួរ និងដែលមានការយល់ដឹងអំពីសំណុំរឿង ០០៣ និង ០០៤ ២៩នាក់ ចង់ឲ្យសំណុំរឿងទាំងនេះបន្តទៅមុខ ខណៈដែលមានតែប្រាំមួយនាក់ប៉ុណ្ណោះដែលមិនប្រាកដ[80]។ មានអ្នកឆ្លើយ១៤នាក់ *មិន* ចង់ឲ្យសំណុំរឿងទាំងនេះបន្តទៅមុខទេ ដោយសារនីតិវិធីវែងឆ្ងាយពេក និង/ឬ បានលើកអំពីកង្វល់នៃការជ្រៀតជ្រែករបស់រដ្ឋាភិបាល និងការភ័យខ្លាចអំពីភាពច្របូកច្របល់ក្នុងសហគមន៍នានា ជាពិសេសអ្នកដែលរស់នៅក្នុងតំបន់ក្បាលរឹងរបស់ខ្មែរក្រហម ឬជាអតីតកម្មាភិបាលខ្លួនឯង[81]។ យ៉ាងណាមិញ ការសិក្សារបស់ OSJI បានកត់សំគាល់ថា ការភ័យខ្លាចរបស់អ្នកឆ្លើយនឹងសំណួរអំពីភាពច្របូកច្របល់ ជាញឹកញាប់ ផ្អែកលើគំនិតយល់ច្រឡំចំនួនពីរថា (i) សំណុំរឿង០០៣ និង០០៤ នឹងកំណត់គោលដៅលើមេដឹកនាំថ្នាក់ទាប និង (ii) មានសំណុំរឿងលើសពី ០០៣ និង ០០៤ ជាបន្តទៀត ដែលជាការធ្វើទៅលើថ្នាក់ក្រោមបន្ថែមទៀតនៃឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ[82]។

33. ការសិក្សាមួយក្នុងឆ្នាំ២០១១ ដែលបានដឹកនាំធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សនៅឯសាលាច្បាប់ Berkeley School of Law បានជ្រើសរើសអ្នកចូលរួមឆ្លើយនឹងសំណួរចំនួន ១,០០០នាក់ ដោយចោះៗពីបណ្តាភូមិចំនួន ២៥០ភូមិ ដើម្បីវាយតម្លៃអំពីចំណេះដឹង គំនិតយល់ឃើញ និងឥរិយាបថរបស់ប្រជាជនកម្ពុជាអំពីការកសាងសង្គមឡើងវិញ និង អ.វ.ត.ក[83]។ មតិភាគច្រើនលើសលប់ (៨៣ ភាគរយ) បានយល់ស្របថា អ.វ.ត.ក គួរតែពាក់ព័ន្ធក្នុងការឆ្លើយតបទៅនឹងអ្វីដែលបានកើតឡើងក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ចំនួន ៩៣ ភាគរយ បានយល់ស្របថា ជាការចាំបាច់ដែលត្រូវស្វែងរកការពិតឲ្យឃើញអំពី អ្វីដែលបានកើតឡើងក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ និង ចំនួន៨៣ ភាគរយ ជឿថា មនុស្សមិនអាចស្ងប់ចិត្តឡើយ ប្រសិនបើគេមិនបានដឹងអំពីអ្វីដែល

---

[79] ការសិក្សារបស់ OSJI, ទំព័រ ១២៦-១២៧, en. 210។ *កត់សំគាល់*ថា អ្នកឆ្លើយត្រូវបានយកពីបញ្ជីទំនាក់ទំនងដែលមានស្រាប់របស់ OSJI នៅកម្ពុជា ដូច្នេះក្រុមដូចគ្នានេះមិនជ្រើសរើសដោយចោះៗនោះទេ។ ក្នុងចំណោមអ្នកឆ្លើយសរុប ១២២នាក់ គឺអ្នកឆ្លើយជាប្រជាជនកម្ពុជាមានចំនួន ១០៩នាក់។

[80] ការសិក្សារបស់ OSJI, ទំព័រ ៨២។

[81] ការសិក្សារបស់ OSJI, ទំព័រ ៨២-៨៣។

[82] ការសិក្សារបស់ OSJI, ទំព័រ ៨៣។

[83] Pham, PN *នឹងគូកន., បន្ទាប់ពីការជំរះក្តីលើកទីមួយៈ ការស្ទាបស្ទង់មតិប្រជាជនស្តីពីចំណេះដឹង និងផ្តត់គំនិតអំពីយុត្តិធម៌ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,* Berkeley: មជ្ឈមណ្ឌលសិទ្ធិ, សកលវិទ្យាល័យកាលីហ្វញ៉ា, ចុះខែមិថុនា ឆ្នាំ២០១១ ("ការសិក្សារបស់ Berkeley"), ទំព័រ ១៦។ *កត់សំគាល់*ថា ទោះបីជាការសិក្សាត្រូវបានបោះពុម្ពផ្សាយក្នុងខែមិថុនា ឆ្នាំ២០១១ ក៏ដោយ ក៏ព័ត៌មានត្រូវបានប្រមូលតាំង២០ថ្ងៃមុន នៃខែធ្នូ ឆ្នាំ២០១០ មកម្ល៉េះ។

បានកើតឡើងចំពោះមនុស្សជាទីស្រឡាញ់របស់ពួកគេ[84]។ គោលបំណងទាំងអស់នេះ នឹងត្រូវបានបំពេញបន្ថែមតាមរយៈការបន្តដំណើរការសំណុំរឿង ០០៣, ០០៤ និង ០០៤/២ ឲ្យទៅមុខ (បើមានភស្តុតាង) ហើយនោះគឺជាគោលបំណងតែមួយគត់ដែលនាំឲ្យមានការបង្កើតតុលាការនេះ។

34. ផ្អែកលើលទ្ធផលទទួលបានពីការសិក្សាទាំងនេះ និងដោយពិចារណាឃើញថា សំណុំរឿង ០០៣, ០០៤ និង០០៤/២ មានបញ្ហា និងទីតាំងឧក្រិដ្ឋកម្មនានាដែលមិនបានដាក់បញ្ចូលជាកម្មវត្ថុនៃសំណុំរឿង ០០១ ឬ ០០២ មានជនរងគ្រោះជាច្រើន និងសមាជិកគ្រួសារនៃជនរងគ្រោះមានចំណាប់អារម្មណ៍ជាខ្លាំង ក្នុងការស្តាប់ការពិតអំពីអ្វីដែលបានកើតឡើងនៅតាមបណ្តាទីតាំងទាំងនេះ និងអំពីអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។ ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១,០៦៣ នាក់ ដែលបានដាក់ពាក្យសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤ និងត្រូវបានបញ្ជាក់ថា អាចទទួលយកបានដោយ ស.ច.ស.អ នោះ[85] ពិតជាមិនបានធ្វើឲ្យពួកគេជឿថា យុត្តិធម៌ត្រូវបានផ្តល់យ៉ាងពេញលេញតាមរយៈសំណុំរឿង ០០១ និង ០០២ នោះទ បើមិនដូច្នោះ ពួកគេមិនដាក់ពាក្យសុំចូលរួមក្នុងសំណុំរឿង ០០៤ ឬមានផែនការប្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ ឡើយ[86]។ លើសពីនេះទៅទៀត សហមេធាវីរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩០១ ដែលត្រូវបានប្រកាសថា មិនអាចទទួលយកបានដោយ ស.ច.ស.អ បានបញ្ជាក់ថា ពួកគេមានបំណងប្តឹងតវ៉ាចំពោះសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបានរបស់ ស.ច.ស.អ នេះ ដើម្បីការពារផលប្រយោជន៍កូនក្តីរបស់ខ្លួន ដើម្បីចូលរួមឲ្យបានពេញលេញក្នុងសំណុំរឿង០០៤ ប្រសិនបើសំណុំរឿងនេះធ្វើដំណើរទៅមុខ[87]។

---

[84] ការសិក្សារបស់ Berkeley, ទំព័រ ២៦, ៣១។ *កត់សំគាល់*ថា តួរលេខទាំងបីនេះ ឆ្លុះបញ្ចាំងលទ្ធផលសិក្សាឆ្នាំ២០១០/២០១១ (ជាជាងលទ្ធផលមូលដ្ឋានឆ្នាំ២០០៨)។

[85] ឯកសារ **D384.1** ឧបសម្ព័ន្ធ ក: បញ្ជីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលអាចទទួលយកបាន, ឧបសម្ព័ន្ធដែលភ្ជាប់ទៅនឹងឯកសារ **D384** ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

[86] ឯកសារ **D381/11** សៀវភៅបណ្តឹងឧទ្ធរណ៍នៃសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (ឯកសារ D381), ១៩ កញ្ញា ឆ្នាំ២០១៩។

[87] *សូមមើល* ឯកសារ **D384.2** ឧបសម្ព័ន្ធ ខ: បញ្ជីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនអាចទទួលយកបាន, ឧបសម្ព័ន្ធដែលភ្ជាប់ទៅនឹងឯកសារ **D384** ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។ ឯកសារ **D384/3** សំណើបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤, ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៩, កថាខណ្ឌ ៩-១២។ ឯកសារ **D384/1** សំណើ

35. ជាសង្ខេប អំណះអំណាងក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ ថា យឹម ទិត្យ មិនគួរប្រឈមមុខនឹងសវនាការជំនុំជម្រះដោយសារ "យុត្តិធម៌ត្រូវបាននាំយកមកជូន" ជនរងគ្រោះហើយ តាមរយៈការជំនុំជម្រះសំណុំរឿង ០០១ និង ០០២" នោះ មិនបានគិតគូរដល់តម្រូវការចាំបាច់ និងបំណងប្រាថ្នាពិតប្រាកដរបស់ជនរងគ្រោះឡើយ[88]។

## III. ដំណោះស្រាយដែលស្នើឡើង

36. ផ្អែកលើមូលហេតុដូចបានពោលខាងលើ ស.ព.អ សូមស្នើឲ្យ អ.ប.ជ ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ តម្កល់សេចក្តីសម្រេចរបស់ ស.ច.ស.អ ដែលថា យឹម ទិត្យ គឺជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបញ្ជូនសំណុំរឿង០០៤ ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានចេញដោយ ស.ច.ស.អ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ | លោកស្រី Brenda J. HOLLIS<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

បន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩, កថាខណ្ឌ ៩-១២។

[88] *ផ្ទុយទៅនឹង* ឯកសារ **D382/4/1** បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ, កថាខណ្ឌ ៧២។